# រឿងឯកសហស្សរាត្រី(១)
# ឬមួយពាន់មួយយប់

## (ជារឿងអារ៉ាប់)

តាមពង្សាវតារស្តេចអំពីបុរាណ ក្នុងដែនពៃរ្សី ដែលបានផ្សាយព្រះរាជអាណាខេត្ត ទៅក្នុងស្រុកឥណ្ឌៀ និងនានាប្រទេស ដែលនៅក្នុងរាជោវាទ នៃស្តេចស្រុកពៃរ្សីព្រមទាំងបរិវេណ ដែលនៅខាងនាយទន្លេគង្គា ដរាបដល់ទល់នឹងស្រុកចិន នោះបានសេចក្តីថាក្នុងកាលជាយូរង្វែងមកហើយ មានស្តេច១អង្គ គ្រងរាជ្យ ក្នុងនគរពៃរ្សីប្រកបដោយសុចរិតយុត្តិធម៌ បច្ចាមិត្រ គ្រប់ទិសានុទិសក៏រអាខ្លបខ្លាចនូវបុញ្ញរិទ្ធិ ហេតុអំពីទ្រង់បានបង្ហាត់បង្វឹកសេនាទាហាន បម្រុងចាំការពារព្រះមហានគរជានិច្ចឥតមានធ្វេសប្រហែសមួយវេលា។

ក្នុងរជ្ជកាលនោះ គ្រឿងឧបភោគបរិភោគចម្រើនសម្បូរហូរហៀរ ឥតមានខ្វះចន្លោះ របស់អ្វីដែលមនុស្សលោកត្រូវការប្រើក្នុងជាន់នោះ។ ព្រះមហាក្សត្រអង្គនេះ មានព្រះរាជបុត្រា២ព្រះអង្គបុត្រច្បងទ្រង់នាមថា សារ្យា ប្រកបដោយរូបឆោមនិងសតិបញ្ញាឥតមាន

---

១- ពាក្យថាឯកសហស្សរាត្រីជាភាសាសំស្ក្រឹត ប្រែថា "មួយពាន់មួយយប់" បានជាខ្ញុំយកមកប្រើក្នុងទីនេះព្រោះយល់ឃើញថាមានសម្លេងពីរោះជាងពាក្យខ្មែរ ។

ល្បៀងអំពីព្រះបិតា ឯព្រះរាជកុមារដែលជាអនុជទ្រង់នាមថា សាសីណង់ ក៏មានលក្ខណៈមិនឃ្លាតឆ្ងាយប៉ុន្មានពីព្រះរៀម ។

លុះគ្រងរាជ្យសម្បត្តិតមកជាយូរអង្វែងឆ្នាំ ស្តេចក៏ទីវង្គតទៅ ទើបព្រះកុមារ សារ្យាជារាជបុត្រច្បងគ្រងជាតំណតព្រះរាជវង្សមក ឯព្រះកុមារ សាសីណង់ គ្មានចំណែកអ្វីក្នុងរាជសម្បត្តិនោះឡើយ ព្រោះច្បាប់សម្រាប់ព្រះនគរមិនត្រូវឱ្យបាន ទ្រង់ក៏ចិញ្ចឹមជីវិតនៅជាប្រក្រតីហាក់ដូចជាជនធម្មតាដូច្នោះឥតមានច្រណែនឫស្យា ដល់ភ័ព្វសំណាងស្តេចព្រះរៀមឡើយ ព្រះហឫទ័យប្រាថ្នាឱ្យតែព្រះរៀមសប្បាយក្នុងរាជសម្បត្តិប៉ុណ្ណោះ។ ព្រះបាទសារ្យាកាលណាបានឃើញអធ្យាស្រ័យ ដ៏ប្រសើររបស់ព្រះអនុជក៏ទ្រង់មានសេចក្តីប្រតិពទ្ធហើយទ្រង់ព្រះតំរិះ នឹងចែកព្រះនគរឱ្យព្រះអនុជគ្រងផង ទើបទ្រង់ប្រគល់ក្រុងតារតារីឱ្យព្រះអនុជ កាលណាបានទទួលយករាជបរិវេណនោះ ក៏តាំងព្រះរាជនិវេសន៍នៅនាតំបន់សាមារកណ្ឌ ។

ស្តេចទាំងពីរព្រះអង្គនេះ គ្រងរាជបានដល់ទៅ១០ឆ្នាំមិនដែលបានយាងទៅមករកគ្នា លុះសម័យ១ព្រះបាទសារ្យាភ្នកព្រះទ័យចង់ជួបនឹងព្រះអនុជ ក៏បានចាត់រាជទូតឱ្យទៅអញ្ជើញព្រះបាទសាសីណង់ដ៏ជាព្រះអនុជមកវេលានោះប្រើអគ្គមហាសេនាឱ្យនាំសកលយោធាសមនឹងរាជសក្តានុភាពទៅហែហម។ លុះរាជទូតទៅទៀបដល់ជិតក្រុងសាមារកណ្ឌ ព្រះបាទសាសីណង់ទ្រង់បានជ្រាបសេចក្តីក៏នាំ



អស់សេនាសេនីយ៍សព្វមុខមន្ត្រី ចេញទៅទទួលដោយរួសរាន់ ហើយដណ្តឹងសួរនូវសុខទុក្ខនៃសម្តេចព្រះរៀមជាដើម ឯអគ្គមហាសេនាដ៏ជារាជទូតក៏ថ្វាយសេចក្តីដោយអណ្តាប់ដរាបដល់អវសាន ទើបក្រាបទូលរឿងដែលខ្លួនទទួលកិច្ចការនាំមក លុះព្រះបាទសាសីណង់បានជ្រាបរឿងច្បាស់សព្វគ្រប់ ក៏មានព្រះបន្ទូល តបនឹងអគ្គរាជទូតវិញថា "ម្នាលអគ្គរាជទូត តាមសេចក្តីដែលអ្នកព័ណ៌នានោះ ឃើញថាសម្តេចព្រះជេដ្ឋាមានសេចក្តីរលឹកនឹកដល់យើងជាខ្លាំង ហេតុនេះយើងមានអំណរពន់ពេកណាស់ ព្រោះសមនឹងគំនិតដែលយើងបានគិតជាយូរហើយ បើដូច្នោះយើងនឹងលើករេហ៍ពលទៅថ្វាយបង្គំដោយរួសរាន់ក្នុងនគរនេះឥតមានចលាចលទេ យើងនឹងរៀបដំណើរឱ្យស្រេចក្នុងរវាង១០ ថ្ងៃដើម្បីនឹងទៅជាមួយនឹងអ្នក វេលានេះសូមអ្នកបោះបារាំភាក់នៅក្រៅក្រុងសិន ខ្ញុំនឹងត្រឡប់ទៅចាត់ការឱ្យរៀបស្បៀងអាហារនាំមកលៀងអ្នកមួយអន្លើ ដោយរេហ៍ពលទាំងអស់ឱ្យបានគ្រប់គ្រាន់បរិបូណ៌" មានព្រះបន្ទូលតែប៉ុណ្ណេះ ក៏នាំសេនាសេនីយ៍សព្វមុខមន្ត្រីចូលទៅក្នុងព្រះរាជនិវេសន៍ ហើយទ្រង់ចាត់ឱ្យនាំស្បៀងអាហារនឹងវត្ថុផ្សេងៗ ដើម្បីជារង្វាន់ដល់យោធាមាត្យគ្រប់ៗគ្នាសុទ្ធសឹងតែជារបស់មានតម្លៃ។

ទើបព្រះបាទសាសីណង់ ទ្រង់ម្ទីម្ទាឱ្យសម្រេចកិច្ចការជាប្រញាប់ឱ្យហើយស្រេច ហើយទ្រង់បានតាំងក្រុមជំនុំឱ្យកាន់កាប់នគរ នៅ

វេលា ដែលទ្រង់ព្រះរាជដំណើរទៅបានចាត់សេនាបតីម្នាក់ដែលមានសតិបញ្ញាមុតមាំជាអធិបតីនៃក្រុមជំនុំនោះ ចាត់ការក្នុងព្រះនគររួចស្រេចកាលណាទ្រង់ក៏ផ្តាំលាព្រះអគ្គមហេសី ហើយលើកឆកលយោធាចេញចាកវាំងជ័យក្នុងវេលារសៀលត្រជាក់ទៅប្រថាប់ក្នុងបារាំព្រះពន្លានៅប្របបារាំអគ្គមហាសេនាដ៏ជារាជទូតព្រះបាទសារ្យា ។ ទ្រង់គង់សន្ទនាជាមួយនឹងអគ្គរាជទូតដរាបដល់ពាក់កណ្តាលអធ្រាត្រ ទ្រង់ភ្នកព្រះហឫទ័យរឭកដល់ព្រះអគ្គមហេសី ក៏ស្តេចត្រឡប់ចូលទៅក្នុងរាជនិវេសន៍វិញតែ១ ព្រះអង្គឯងក្នុងរាត្រីនោះ ឯព្រះអគ្គមហេសីគិតស្មានថាព្រះស្វាមីមិនត្រឡប់មកវិញទេ ក៏នាំប្រុសសហាយម្នាក់ដែលជាមហាតលិកទៅរួមវេណីជាមួយ ហើយដេកលក់ទាំងពីរអ្នកតាំងពីបឋមយាមមក ។

ព្រះបាទសាសីណង់ស្តេចមកដល់កាលណា ក៏យាងព្រះបាទថ្នមៗចូលទៅ ដើម្បីធ្វើកុំឱ្យព្រះអគ្គមហេសីភ្ញាក់នឹងព្រះអង្គ ព្រោះទ្រង់ស្មានថា ព្រះទេវីមានព្រះហឫទ័យស្មោះត្រង់ លុះយាងចូលទៅដល់ក្រឡាព្រះបន្ទំទ្រង់ទតទៅឃើញព្រះអគ្គទេពី កំពុងផ្ទំឱបប្រុសសហាយនៅលើព្រះទែន ក៏ទ្រង់ស្លុតព្រះហឫទ័យ ហើយទ្រង់ប្រតិស្ថានជញ្ជឹងមួយស្របក់ ដើម្បីសង្កេតឱ្យច្បាស់ក្រែងព្រឹលព្រះនេត្រទេដឹង លុះបានមួយស្របក់ទៅ ទ្រង់ឈ្វេងយល់ថា មិនមែនជាស្រមៃទេ ទើបទ្រង់ពិចារណាថា “ឱអនិច្ចា ! កម្មអើយកម្មខ្លួនអញមិនទាន់ចេញផុត





ស្រឡះពីក្រុងសាមារក័ណ្ឌនៅឡើយ វាហ៊ានក្បត់ចិត្តអញដល់ម្លេះ អញមិនត្រូវបង្អង់ទោស មេចង្រៃកាឡកណ្ណីនេះឡើយ ខ្លួនអញជាស្តេចគួរឱ្យផ្តន្ទាបទល្មើស ដែលកើតក្នុងអាណាខេត្តអញ ខ្លួនអញជាស្វាមីត្រូវអញផ្ទាល់ឱ្យសមនឹងទោស ។ គិតតែប៉ុណ្ណោះហើយ ក៏ហូតព្រះខ័នយាងចូលទៅជិតប្រហារសហាយ ទាំងពីរកំពុងដេកលក់ដល់នូវមរណៈក្នុងវេលានោះស្រេចហើយ ទ្រង់ក៏ទាញយកម្តងមួយទៅទម្លាក់ចោលក្នុងជ្រោះដែលជីកជុំវាំង » ។

ស្រេចហើយកាលណា ទ្រង់ក៏ចេញពីព្រះរាជវាំងដោយស្ងាត់ៗ ទៅវិញយាងចូលទៅក្នុងបារាំព្រះពន្លាដើមឥតប្រាប់អ្នកឯណាឱ្យដឹងអំពីរឿងនេះឡើយ ហើយទ្រង់បង្គាប់ឱ្យលើករេហ៍ពលទៅក្នុងរាត្រីនោះ អស់សេនាយោធាក៏ម្នីម្នាប្រជុំកងទាហាន ហើយប្រគុំតូរ្យតន្ត្រីផ្លុំត្រែស័ង្ខឮកងរំពង ទើបត្រាច់ពនេចរតតាមមាគ៌ាទៅកាលនោះ ព្រះបាទសាសីណង់ទ្រង់មានបរិវិតក្កជាអនេកដោយទ្រង់រំពឹងនឹកដល់រឿងព្រះអគ្គមហេសី ព្រះឱរាចង្អៀតចង្អល់ជានិច្ច តែមួយព្រះអង្គឯង ។

លុះទ្រង់យាងឡើបដល់ក្រុង ស៊ុលតង់[១] សារ្យាជាជេដ្ឋាស្តេចចេញមកទទួលមួយអន្លើដោយសេវកាមាត្យជាច្រើន ហើយនៅវេលាដែលបានជួបក្រស័ត្រទាំងពីរអង្គក៏ចុះពីខ្នងអស្សរតរ ស្ទុះចូលទៅគំនាប់

១- ពាក្យស៊ុលតង់ជាពាក្យ អារ៉ាប់ ប្រែថាស្តេច បើជាអគ្គមហេសីហៅថា ស្រីស៊ុល-តាន ។



ថ្លែងសេចក្តីប្រាស្រ័យកាន់គ្នា ហើយក៏ប្រកៀកប្រឱបតាមដោយសេចក្តីរលឹកដែលខានឃើញគ្នាជាយូរឆ្នាំ លុះបានស្រោកស្រាន្តព្រះហឫទ័យក៏ស្តេចឡើងអាជានេយ្យយាងចូលទៅក្នុងព្រះរាជវាំង ព្រមទាំងសេនាយោធាហែហមមុខក្រោយ លុះដល់ព្រះរាជដំណាក់ហើយ ស៊ុលតង់សារ្យាក៏នាំព្រះអនុជាធិរាជទៅប្រថាប់ក្នុងដំណាក់មួយ ទន្ទឹមគ្នានឹងដំណាក់ព្រះអង្គដែលមានសួនច្បារមួយឃ្លាំងនៅកណ្តាលជាកន្លែងសម្រាប់រៀបធ្វើពិធីបុណ្យផ្សេងៗ ហើយមានទាំងប្រដាប់ប្រដាឥតមានខ្វះអ្វីផង ។

កាលណាបានប្រគល់ ដំណាក់ថ្វាយព្រះអនុជរួចហើយ ស៊ុលតង់សារ្យាក៏ស្តេចទៅកាន់ទីដទៃ ដើម្បីឱ្យព្រះអនុជាធិរាជចូលស្រង់គង្គា លុះព្រះអនុជបានស្រង់នឹងតែងព្រះអង្គស្រេច ទើបស្តេចមកជួបវិញគង់សន្ទនាអំពីកិច្ចការផ្សេងៗ នូវសេចក្តីសុខទុក្ខក្នុងរវាង ដែលឃ្លាតចេញពីគ្នាជាយូរអង្វែងឆ្នាំ នាកណ្តាលមន្ត្រីដែលអង្គុយគាល់ ដោយជុំវិញ ។ ដល់ពេលសោយ ក្រស័ត្រទាំងពីរព្រះអង្គក៏ទ្រង់សោយជាមួយគ្នា សោយស្រេចវេលាណា ក៏គង់សន្ទនាតទៀត ដរាបរាត្រីស្ងាត់ ទើបព្រះបាទសារ្យាលាព្រះអនុជទៅ ដើម្បីឱ្យព្រះអនុជបានសម្រាកព្រះកាយពល ។

ព្រះបាទសាសីណង់ក៏យាងចូលក្នុងក្រឡាព្រះបន្ទំ ដើម្បីសំងំផ្ទំក្នុងវេលានោះ ក្នុងពេលដែលសម្តេចព្រះជេដ្ឋាគង់សន្ទនាជាមួយ

ហាក់ដូចជាបានរយាលស្បើយ នូវសេចក្តីវិតក្កនោះខ្លះ តែលុះវេលាដែលសំងំតែមួយព្រះអង្គឯងបន្តិចទៅ សេចក្តីវិតក្កនោះក៏ច្រឡោតឡើង នាំឱ្យកើតរសាប់រសល់ឈឺឆ្អៀបព្រោះព្រះហឫទ័យ ប្រវត្តិតែទៅរឿងព្រះអគ្គជាយាទុច្ចរិត ប្រៀបបីដូចជាគោដែលត្រូវគេចាក់ដោយជន្លួញ បានសេចក្តីឈឺចាប់យ៉ាងណា ឬសេចក្តីក្តៅផ្សាដោយស្រ្តីក៏ឈឺចាប់យ៉ាងដូច្នោះ ម្ល៉ោះហើយទ្រង់ក្រោកចេញពីក្រឡាព្រះបន្ទំគង់តម្រង់កាយសញ្ជឹងតែមួយព្រះអង្គអស់រាត្រីនោះ ទ្រង់មានព្រះភក្រ្តសៅហ្មង ដោយអំណាចទុក្ខជាខ្លាំង ។ ឯស៊ុលតង់សារ្យាសម្គាល់ឃើញ ថាព្រះអនុជមិនសប្បាយដូច្នោះទ្រង់ព្រះតំរិះថា (ចុះប្អូនអញមានរឿងអ្វីកើតទុក្ខ អផ្សុកដោយហេតុយ៉ាងណា នរណាធ្វើឱ្យអាក់អន់ ឬមួយតូចចិត្តថាអញរៀបទទួលមិនគួរសម តែតាមអញធៀបមើលទៅឃើញថាការដែលអញរៀបទទួលនេះគួរ និងស័ក្តិប្អូនសំឡាញ់អញណាស់ហើយ ឥតមានទាស់ឆ្គងត្រង់ណាទេ ឬមួយជាមានសេចក្តីព្រួយរឭកដល់នគរនឹងដល់អគ្គមហេសី ប្រសិនបើដូច្នេះត្រូវអញឱ្យរបស់ប៉ុន្មាន ដែលអញបម្រុងនឹងឱ្យដល់ប្អូនអញ ដើម្បីបើមានប្រាថ្នានឹងវិលទៅនគរវេលាណាក៏ទៅបាន មិនទើសទាល់ព្រោះហេតុមិនហ៊ានលាអញទៅ លុះព្រឹកឡើងទ្រង់ក៏ចាត់ឱ្យនាំដង្វាយផ្សេងៗ យកមកព្រះរាជទានសុទ្ធ សឹងតែវត្ថុដ៏មានតម្លៃ រកបានដោយក្រដែលមានក្នុងប្រទេសនោះ។ រួចទ្រង់ចាត់ឱ្យធ្វើបុណ្យមានលេងល្បែងប្លែក ដើម្បី



ជាទីកំសាន្តដល់ព្រះអនុជ ប៉ុន្តែព្រះអនុជឥតមានស្រាកសេចក្តីវិតក្កនោះឡើយរឹងរឹតតែទ្វេទុក្ខឡើងទៀត ។

មានថ្ងៃមួយព្រះបាទសារ្យា បានចាត់យោធាដើម្បីចេញទៅបណ្តេញសត្វព្រៃចម្ងាយពីរថ្ងៃ ពីទីក្រុងហើយនាំព្រះអនុជទៅក្រសាលជាមួយផង ប៉ុន្តែក្នុងវេលានោះព្រះអនុជសុំខាន ទូលថាមានប្រឈួននឹងទៅក្រសាលមិនបាន ព្រះជេដ្ឋាក៏មិនហ៊ានបង្ខំ បណ្តោយឱ្យព្រះអនុជនៅជាសុខក្នុងព្រះរាជវាំង ហើយស្តេចចេញទៅតែមួយព្រះអង្គឯងមួយអន្លើដោយសេនាទាហាន ។ ឯព្រះបាទសាសីណង់គង់នៅក្នុងព្រះដំណាក់តែឯង ហើយសញ្ជឹងសញ្ជប់នៅបង្អួចដែលឆ្ពោះទៅសួនច្បារដ៏មានដើមឈើធំៗ ជាច្រើនមានបក្សីគ្រប់យ៉ាង។ តាំងទ្រនំនៅជានិច្ចក្នុងទីនោះ ហើយស្រែកយំទ្រហឹងស៊ានតាមភាសាវាទីទៃៗ គួរជាទីសប្បាយដល់មនុស្សដែលគ្មានទុក្ខ ប៉ុន្តែឯព្រះបាទសាសីណង់ ក៏គ្មានសេចក្តីស្បើយក្នុងព្រះឱរា រួចពីសម្លឹងមើលព្រឹក្សាលតាវល្លិ៍ក្នុងសួនច្បារ ងើបព្រះភក្រ្តាទតឡើងទៅលើមេឃ ហើយពោលត្អូញត្អូរពីកម្មអកុសលនឹងភ័ព្វសំណាងអាក្រក់ដែលផ្តល់មក ។

ក្នុងវេលានោះទ្រង់ឆ្មៀងព្រះនេត្រទត ត្រង់ទៅទ្វារសម្ងាត់នៃប្រាសាទព្រះជេដ្ឋា ស្រាប់តែឃើញទ្វារនោះបើកឡើងហើយឃើញស្រ្តី ២០ នាក់ចេញមក ឃើញអគ្គទេវី នៃព្រះជេដ្ឋានៅកណ្តាលស្រ្តីទាំងនោះ ។ រីព្រះនាងគិតស្មានថា ស៊ុលតង់សាសីណង់ចេញទៅជាមួយនឹង

ស្វាមីទើបនាំស្រីស្នំទាំងនោះឆ្ពោះទៅកាន់ដំណាក់ ដែលស្ដេចសាសីណង់គង់តែស្ត្រីទាំងអស់សុទ្ធតែគ្របមុខមិនឱ្យឃើញ តាមទំនៀមស្រុក លុះមកជិតដំណាក់កាលណា ក៏បើកមុខឡើងទាំងអស់គ្នា ឯស្ដេចសាសីណង់ពួននៅក្បែរបង្អួចលបមើលមិនឱ្យស្រីទាំងនោះឃើញ ។ កាលណាបើកមុខហើយ ស្ត្រីទាំងនោះក៏ដោះអាវវែងខាងក្រៅនៅសល់តែអាវខ្លីជាន់ក្នុងព្រះបាទសាសីណង់មានសេចក្ដីឆ្ងល់ណាស់ ព្រោះឃើញក្នុងចំណោមនោះមានមនុស្សប្រុសខ្មៅ១០នាក់ ដែលទ្រង់ស្មានថា ជាស្ត្រីទាំងអស់ ហើយប្រុសទាំងនោះក្បៀកស្ត្រីមួយម្នាក់ៗ ដែលជាសហាយរបស់ខ្លួន ឯចំណែកព្រះអគ្គទេវីក៏មិននៅឥតគូដែរ យូរបន្តិចដោះអាវហើយទះដៃផ្ទូងៗ ស្រែកហៅថា "មាសូទៗ" ក្នុងគ្រានោះឃើញប្រុសខ្មៅម្នាក់ទៀតចុះពីលើដើមឈើ ហើយរត់ទៅឱបព្រះរាជទេវី ។

កិរិយាដែលបុរសនឹងស្ត្រីទាំងនេះ ប្រព្រឹត្តក្នុងវេលានោះខ្ញុំមិនអាចនឹងពោលឱ្យសព្វគ្រប់ទៅបានឡើយ ដោយច្បាប់កេរ្តិ៍ខ្មាសមិនអនុញ្ញាតឱ្យ ហើយជាការដែលគេតែងតែដឹងគ្រប់គ្នា គ្រាន់តែថាក្នុងវេលានោះ ព្រះបាទសាសីណង់បានសង្កេតឃើញច្បាស់គ្រប់ស្ថានហើយមកគិតថា "សម្ដេចព្រះរៀមមិនមែនមានអកុសលតិចជាងទ្រង់ឡើយ សេចក្ដីតម្រេកក្នុងកាមគុណរបស់សហាយទាំងនេះ សម្ដែងនៅក្នុងទីដដែល ដរាបដល់ពាក់កណ្ដាលអធ្រាត្រ ទើបនាំគ្នាចុះងូតទឹក



ស្រះក្នុងសួនច្បារនោះទាំងអស់គ្នា ស្រេចហើយកាលណា ក៏ស្លៀកពាក់នាំគ្នាចូលទៅក្នុងដំណាក់តាមទ្វារដដែលនោះវិញ ឯចំណែកមាសូទដែលជាសហាយរបស់ព្រះអគ្គទេវី ជាមនុស្សខាងក្រៅក៏ចេញទៅតាមកន្លែងដដែលដែលបានចូលមក" ។

កាលទ្រង់បានទស្សនាការអំពើទាំងនេះ ច្បាស់នឹងព្រះនេត្រហើយក៏មកឈ្វេងក្នុងព្រះហឫទ័យថាអញ "គិតពេញជាខុសសោះដែលស្មានថាក្នុងលោកនេះ មានតែខ្លួនអញមួយជាមនុស្សឥតភព្វជាងគេ អកុសលនេះធ្លាក់លើច្រើនប្រុសដែលមានភរិយាបានជាថាដូច្នេះព្រោះឃើញថាអម្បាលដល់ ស៊ុលតង់ បងអញជាមហាក្សត្រធំបំផុតក្នុងលោកម្ដេចក៏ទ្រង់ជៀសអកុសលនេះមិនផុត ឯខ្លួនអញនេះសោតជាមនុស្សទន់ខ្សោយណាស់ បានជាបណ្ដោយឱ្យទុក្ខមកញាំញីបាន ចាប់ដើមពីពេលនេះតទៅ អញមិនត្រូវបើកឱកាសទុក្ខមកជ្រៀតជ្រកនៅបាន" លុះទ្រង់ព្រះចិន្ដាដូច្នេះហើយ សេចក្ដីវិតក្កទាំងប៉ុន្មាន ដែលមានក្នុងព្រះឱរាក៏រសាយបាត់អស់ សោយក្រយាស្ងោយក៏មានឱជារសព្រះកាណិក៏ទទួលសណ្ដាប់នូវភ្លេងមហោស្រពដែលលេងថ្វាយ ព្រោះតាំងពីទ្រង់យាងចេញពីក្រុងសាមារក័ណ្ឌមក ទ្រង់មិនដែលបានសោយដោយមានឱជារសដូច្នេះ ហើយទ្រង់មិនដែលបានក្រសាលនឹងមហោស្រពសោះ ។

ថ្ងៃក្រោយមកទៀត សេចក្ដីតម្រេកក៏រឹតតែកើតមានក្នុងព្រះ

អង្គ លុះបានជ្រាបជាព្រះជេដ្ឋាត្រឡប់មកពីប្រពាតព្រៃ ក៏ស្តេចចេញទៅគាល់ដោយរួសរាយរាក់ទាក់ ។ ដើមឡើយ ស៊ុលតង់សារ្យាមិនបានជាពិនិត្យដល់ហេតុដែលនាំឱ្យព្រះអនុជប្រែប្រួក ទ្រង់មានបន្ទូលតែអំពីស្តាយមិនបានព្រះអនុជទៅក្រសាលជាមួយ ហើយព្រះអនុជមិនទាន់ទាំងបានឆ្លើយតបថាដូចម្តេច ទ្រង់មានបន្ទូលទៀតអំពីសេចក្តីសប្បាយក្នុងការប្រពាតព្រៃ អំពីចាប់សត្វម្រឹគផ្សេងៗបានជាច្រើន។ ខណៈនោះព្រះបាទសាសីណង់ទ្រង់ស្តាប់ព្រះរៀមលុះចប់សេចក្តីហើយ ដោយទ្រង់គ្មានទុក្ខអ្វីក្នុងព្រះអង្គ ទ្រង់ក៏ព័ណ៌នាតបទៅព្រះរៀមដោយការរួសរាយអំពីរឿងផ្សេងៗ តាមដែលទ្រង់នឹកឃើញក្នុងវេលានោះ ។

ឯស៊ុលតង់សារ្យា គិតស្មានថា ព្រះអនុជនៅមានទុក្ខដូចដែលក៏ភ្ញាក់ស្មារតី វេលាដែលឃើញភក្ត្រាព្រះអនុជស្រុះស្រួល ហើយរួសរាយទើបទ្រង់មានព្រះរាជឱង្ការទៅកាន់ព្រះអនុជថា "ប្អូន ! បងសូមអរគុណដល់ព្រះជាម្ចាស់ ដែលបានផ្លាស់ប្រែកិរិយាប្អូនក្នុងពេលដែលបងមិននៅបងមានសេចក្តីអំណរហួសប្រមាណ ដែលបានឃើញប្អូនបានសេចក្តីរីករាយដូច្នេះ ប៉ុន្តែបងសូមសួរប្អូនបន្តិច សូមឱ្យប្អូនអនុញ្ញាតតបសេចក្តីដែលបងសួរទាំងប៉ុន្មាន" ព្រះអនុជតបទៅវិញថាទូលព្រះបង្គំជាខ្ញុំមិនអាចនឹងរាំងរាព្រះជេដ្ឋាទេ បើព្រះជេដ្ឋាសព្វព្រះហឫទ័យសួរពីរឿងអ្វីទូលបង្គំ នឹងសូមឆ្លើយថ្វាយគួរនឹងការ សូមព្រះជេដ្ឋាសួរមកចុះ ទូលបង្គំជាខ្ញុំចង់ដឹងរឿងដែលព្រះអង្គសួរដែរ ព្រះ



បាទសារ្យាមានបន្ទូលសួរថា "តាំងពីប្អូនចូលមក ដល់ទីក្រុងបងវេលាណាបងសម្គាល់ឃើញប្អូនស្រងូតស្រងាត់ជានិច្ច បងខំធ្វើឱ្យប្អូនរសាយនូវសេចក្តីស្រងូតស្រងាត់នោះ គ្រប់បែបយ៉ាងតែមិនបានការអ្វីសោះ ហើយបងគិតឃើញថា ដែលប្អូនកើតទុក្ខនេះ គឺបណ្តាលមកអំពីការដែលប្អូនបោះបង់ចោលនគរ ឯសេចក្តីស្រងូតស្រងាត់នេះប្រហែលកើតអំពីសេចក្តីស្នេហាដល់អគ្គជាយា ព្រោះវេលាដែលប្អូនរើសអគ្គមហេសីនោះ គឺរើសយកស្ត្រីដែលប្រកបដោយលក្ខណៈរូបឆោម ហើយបងស្មានថាអគ្គមហេសីប្អូននេះហើយ ជាដើមឫសនៃសេចក្តីវិតក្ករបស់ប្អូន ប៉ុន្តែមិនដឹងជាគំនិតដែលបងគិតឃើញនេះត្រូវឬខុសព្រោះតែបងគិតឃើញដូច្នេះហើយបានជាបង យល់ថាមិនត្រូវឱ្យប្អូនទើសទាល់មិនហ៊ានលាបង បងរៀបរបស់ទាំងប៉ុន្មានដែលបម្រុងនឹងថ្វាយប្អូនយកទៅថ្វាយ ដើម្បីឱ្យប្អូនចង់វិលទៅនគរវេលាណាក៏បាន ប្អូនក៏នៅតែស្រងូតស្រងាត់ព្រះភ័ក្ត្រដដែល លុះបងត្រឡប់មកពីចាប់សត្វនេះស្រាប់តែឃើញកិរិយាប្អូនផ្លាស់ទៅជារីករាយបាត់កើតទុក្ខវិញ ហេតុនេះ សូមឱ្យប្អូនប្រាប់បងដោយត្រង់ ចុះហេតុអ្វីបានជាប្អូនស្រងូតស្រងាត់? ហើយចុះហេតុអ្វីបានជារីករាយឡើងវិញ?"

កាលណាចប់សេចក្តីខាងលើនេះ ព្រះបាទសាសីណង់ជាប្អូនសញ្ជឹងស្ញៀមនៅមួយស្របក់ដូចជារកនឹកសេចក្តីនឹងឆ្លើយតបទៅវិញទើបឆ្លើយទូលថា "ព្រះអង្គជាស៊ុលតង់របស់ទូលបង្គំ ជាម្ចាស់លើ

សិរសាទូលបង្គំ ប៉ុន្តែក្នុងវេលានេះ សូមព្រះអង្គទ្រង់អនុញ្ញាតកុំឱ្យទូលបង្គំជាខ្ញុំឆ្លើយ” ព្រះបាទសារ្យាមានបន្ទូលតទៅទៀតថា ត្រូវតែប្អូន និយាយប្រាប់បងខានមិនបាន ព្រោះបងបានសូមអនុញ្ញាតជាស្រេច ហើយឯព្រះបាទសាសីណង់ស្ងៀមមិនបាន ក៏មានបន្ទូលថា “បើព្រះជេដ្ឋា ទទូចសួរទូលបង្គំដូច្នេះទូលបង្គំនឹងថ្វាយសេចក្តី” ទើបអធិប្បាយតាំងអំពីព្រះអគ្គមហេសីផិតក្បត់ ដរាបដល់ចប់រឿង ហើយទូលទៅព្រះរៀមថា “នេះហើយជាដើមហេតុដែលនាំឱ្យទូលព្រះបង្គំជាខ្ញុំស្រងូតស្រងាត់សូមទ្រង់ជ្រាប” វេលានោះស៊ុលតង់សារ្យាតបទៅវិញថា រឿងដែលប្អូននិយាយនេះជារឿងអព្វមង្គលសមនឹងប្អូនផ្តន្ទាមនុស្សក្បត់ដល់ទីនេះគ្មានអ្នកណាឯណាបន្ទោសប្អូនឡើយ ព្រោះបានធ្វើសមនឹងបទល្មើសនោះណាស់ បងប្រាប់ប្អូនដោយត្រង់ចុះ ប្រសិនបើខ្លួនបងវិញប្រហែលជាធ្វើលើសប្អូនទៅទៀត គឺថាជីវិតស្ត្រីម្នាក់មិនធួនទេ ត្រូវសម្លាប់យ៉ាងតិច ១០០០នាក់ទើបធួន នឹងកំហឹងបង វេលានេះបងអស់សន្ទិះសង្ស័យហើយ ព្រោះដឹងថាទុក្ខប្អូនមានដើមកំណើតមាំពន់ប្រមាណណាស់ តាមដោយបងស្មានឃើញ ថាមនុស្សក្នុងលោកនេះគ្មាននរណាមួយអភព្វជាងប្អូនទេ រឿងដូច្នេះមានលើតែប្អូនម្នាក់ឯង គ្មាននរណាមានរឿងហេតុដូច្នេះឡើយ ប៉ុន្តែត្រូវតែរលឹកដល់គុណព្រះជាម្ចាស់ដែលលោកបានធ្វើឱ្យប្អូនមានសេចក្តីរីករាយឡើងវិញ តែដោយបងជឿជាក់ថា ក្នុងវេលានេះប្អូនអស់សេចក្តីវិតក្ក ស្រឡះពីខ្លួនហើយ



ត្រូវតែប្អូនប្រាប់រឿងដែលនាំឱ្យប្អូនបាត់ទុក្ខនេះ ឱ្យបងដឹងផង តើបណ្តាលមកពីហេតុអ្វី?

សេចក្តីសួរលើកទី ២ នេះនាំឱ្យព្រះបាទសាសីណង់រួញអល់ឯកលើសរឿងដំបូង ព្រោះរឿងនេះមានទាក់ទាមដល់ព្រះរៀម “ប៉ុន្តែនឹងទប់មិននិយាយមិនបាន ព្រោះព្រះរៀមបង្ខំជាពន់ពេកណាស់ ។ មុននឹងចាប់ផ្តើមរឿងឡើង ទ្រង់ទូលព្រះរៀមថា បើព្រះជេដ្ឋាសព្វព្រះហឫទ័យ ទូលព្រះបង្គំជាខ្ញុំនឹងទទួលតាមតែទូលព្រះបង្គំពិភាល់ក្នុងចិត្តថា ក្រែងទទួលតាមព្រះរាជតម្រាស់ទៅ នាំឱ្យកើតទោសដល់ព្រះអង្គដោយរឿងនេះ ព្រោះព្រះអង្គបង្ខំឱ្យទូលព្រះបង្គំថ្វាយសេចក្តីដែលទូលព្រះបង្គំនាំឱ្យខ្ញុំប្រែចិត្តកើតមានរីករាយឡើងវិញ” វេលានោះព្រះបាទសារ្យាឆ្លើយកាត់ថា “មិនអីទេ ! រឿងដែលប្អូននិយាយនោះនាំឱ្យរឹតតែចង់ស្តាប់ទៅទៀត ” ចូរប្អូននិយាយឱ្យឆាប់ទៅរឿងអ្វីក៏ដោយឱ្យតែពិត តាមការដែលកើតឡើង កាលណាអាក់ខានពុំបាន ព្រះបាទសាសីណង់ក៏ព័ណ៌នាតាំងអំពីដែលបានឃើញមនុស្សខ្មៅ១ ក្លែងភេទជាស្ត្រីអំពីកាមរាគរបស់ព្រះអគ្គទេវីនឹង បណ្តាស្រីស្នំក្រមការទាំងប៉ុន្មានព្រមទាំងមាសូទដែលជាសហាយរបស់ព្រះអគ្គមហេសីនៃព្រះរៀម ទ្រង់សារស័ព្ទតាមដែលបានឃើញគ្រប់ស្ថាន ឥតមានភ្លេចកន្លែងណា ចប់រឿងហើយ ទ្រង់ទូលព្រះរៀមតទៅថា “នៅវេលាដែលបានឃើញអំពើអាក្រក់នេះ ទូលបង្គំពិចារណាថា ស្ត្រីទាំងអស់តែងតែដូច្នេះ តែ

កាលណាបាក់ចិត្តទៅខាងណា មិនអាចនឹងទប់ចិត្តវិញបាន លុះគិតឃើញដូច្នេះហើយ ទូលបង្គំសន្និដ្ឋានថា បុរសណាតែជាប់ទុកចិត្តទៅលើកិរិយាមារយាទរបស់ស្ត្រីណាហើយ បុរសនោះគេហៅថាជាមនុស្សខ្សោបខ្សោយ ជាមនុស្សមានសភាពទន់ជុនដាប ទូលបង្គំពិចារណាឃើញហេតុជាច្រើនទៅទៀត បានជាខំកាត់ចិត្តលះបង់នូវសេចក្តីវិតក្កស្រងូតស្រងាត់ចេញ លុះដល់បានសម្រេចដូចសេចក្តីប្រាថ្នា ប្រសិនបើព្រះជេដ្ឋាជឿរឿងដែលទូលបង្គំប្រាប់នេះ សូមទ្រង់យកតម្រាប់តាមដែលទូលបង្គំបានធ្វើនោះ ឃើញជាការស្រួលល្អ" ។

ឯស៊ុលតង់សារ្យាវេលាដែលបានទ្រង់ព្រះសណ្តាប់នូវវាចានៃព្រះអនុជទាំងប៉ុន្មានហើយ ក៏ទ្រង់ឥតជឿព្រះអនុជបន្តិចសោះ ព្រះហឫទ័យចង់ខ្ចាល់នឹងព្រះអនុជវិញផងហើយមានបន្ទូលថា "ពាក្យដែលប្អូននិយាយនេះជាពាក្យមិនពិតទេ ព្រះអគ្គមហេសីបងមិនអាចនឹងប្រព្រឹត្តអំពើលាមកក្បត់បងដូច្នេះឡើយ បងជឿប្អូនលុះតែបងបានឃើញច្បាស់នឹងភ្នែកបង ប្រហែលជាប្អូនភាន់ច្រឡំទេដឹង? ដោយរឿងនេះ ជារឿងធំត្រូវបងចាំបញ្ជាក់នឹងភ្នែកបងឱ្យច្បាស់សិន" វេលានោះ ព្រះបាទសាសីណង់ទូលតបវិញថា ប្រសិនបើព្រះជេដ្ឋាចង់ច្បាស់នោះ ជាការងាយណាស់ ព្រះអង្គធ្វើជាចេញទៅចាប់សត្វម្តងទៀតជាមួយនឹងទូលបង្គំជាខ្ញុំ នាំទាំងនាហ្មឺនសព្វមុខមន្ត្រីរបស់ព្រះអង្គនឹងរបស់ទូលបង្គំជាខ្ញុំទៅទាំងអស់គ្នា លុះយើងទៅប្រថាប់ក្នុងព្រះពន្លា



នៅក្រៅក្រុងហើយ យើងត្រឡប់មកវិញតែ២នាក់ ចូលមកពួននៅក្នុងដំណាក់ដែលទូលបង្គំជាខ្ញុំនៅ ទូលបង្គំជាខ្ញុំថាប្រាកដជាព្រឹកស្អែកទ្រង់នឹងបានឃើញដូចកាលដែលទូលបង្គំជាខ្ញុំឃើញមិនខាន" ព្រះបាទសារ្យាក៏ទ្រង់យល់ព្រមតាម ហើយបានចាត់ការឱ្យទៅសង់ព្រះពន្លានៅកន្លែងមួយក្នុងព្រៃដែលបានសម្រេចទុក ។

ថ្ងៃក្រោយតពីនោះមក ក្សត្រទាំង២យាងចេញមួយអន្លើ ដោយសេវកាមាត្យជាច្រើន លុះបានដល់ទីព្រះពន្លាហើយទ្រង់ចូលសម្រាកព្រះកាយក្នុងទីនោះដរាបដល់រាត្រីស្ងាត់ ទ្រង់ត្រាស់ហៅអគ្គមហាសេនាមកផ្តាំឱ្យនៅថែទាំព្រះពន្លា ហាមផ្តាច់មិនឱ្យមនុស្សណាចូលដល់ក្រឡាបន្ទំ តែទ្រង់មិនបានប្រាប់អំពីសេចក្តីប្រាថ្នារបស់ទ្រង់ឡើយ ផ្តាំស្រេចហើយ ទ្រង់ឡើងគង់លើអាជានេយ្យជាមួយនឹងព្រះអនុជាធិរាជយាងត្រឡប់ចូលមកក្នុងនគរវិញ ប្រថាប់ក្នុងដំណាក់ដែលព្រះបាទសាសីណង់សម្រាកនៅ ហើយក៏ផ្ទំទាំងពីរព្រះអង្គនៅទីនោះ លុះវេលាព្រឹកឡើងទ្រង់យាងទាំងពីរព្រះអង្គទៅគង់នៅព្រះកៅវតា ទ្រង់គង់ក្រសាលយកសន្សើមនៅទីបង្អួចដោយក្នុងវេលានោះព្រះអាទិត្យមិនទាន់រះនៅឡើយ តែទ្រង់ឆ្មៀងព្រះនេត្រញយៗ នៅទីទ្វារតូចនោះតែមួយស្របក់ទើបឃើញទ្វារនោះរបើកឡើង ហើយឃើញព្រះអគ្គមហេសីចេញមកព្រមដោយស្រីស្នំក្រមការ នឹងមនុស្សខ្មៅ ១០នាក់នោះ ហើយឃើញទាំងស្រែកហៅឈ្មោះមាសូទ ដែលជាសហាយ

របស់ព្រះអគ្គទេវីផង ។ ស៊ុលតង់សារ្យាបានឃើញ ហេតុភេទជាក់ស្តែងទាំងអស់ឥតមានខុសអំពីព្រះអនុជទូលទ្រង់ ក៏មានសេចក្តីអៀនខ្មាសជាខ្លាំង អំពីទុក្ខធំដែលធ្លាក់លើព្រះអង្គហើយ ទ្រង់ស្រែកថ្ងូញថា ឱព្រះម្ចាស់ថ្លៃអើយ ខ្ញុំហួសចិត្តណាស់អកុសលអ្វីម្ល៉េះ អម្បាលដល់អគ្គមហេសីនៃមហាក្សត្រមានឫទ្ធានុភាពដូចយ៉ាងខ្ញុំនេះ គង់ប្រព្រឹត្តអំពើលាមកដូច្នេះបាន បើយ៉ាងនេះតើមានក្សត្រណាក្រៅអំពីខ្ញុំ នឹងអួតអាងថាខ្លួនប្រកបដោយសុខនិរទុក្ខទៅបាន? រួចទ្រង់ស្ទុះទៅឱបព្រះអនុជហើយមានបន្ទូលថា “នែប្អូន ! យើងទាំងពីរនាក់ត្រូវកុំនៅក្នុងព្រះនគរយើងនេះ គ្មានមនុស្សបញ្ជោរនិងក្បត់ទាំងអស់ត្រូវយើងទៅពឹងពាក់លាក់ខ្លួន ក្នុងប្រទេសដទៃកុំឱ្យមានអ្នកណាដឹងស្គាល់យើង ព្រះបាទសាសឺណង់មិនព្រមតាម តែទ្រង់មិនអាចទទឹងនឹងព្រះរៀម ទើបទ្រង់ទូលតបទៅវិញ បពិត្រព្រះជេដ្ឋាប្អូនឥតមានទទឹងទាស់អ្វីនឹងព្រះហឫទ័យទេ ប៉ុន្តែសូមឱ្យព្រះអង្គសន្យានឹងទូលបង្គំថា យើងត្រូវត្រឡប់មកនគរវិញ កាលណាបើយើងបានឃើញមនុស្សដែលមានអកុសលក្រាស់ជាងយើងទៅទៀត ព្រះបាទសារ្យាឆ្លើយតបថា មិនអីទេ បងនឹងសន្យាឱ្យ តែបងស្មានមើលទៅច្បាស់ជាគ្មានអ្នកឯណាមួយជាមនុស្សអកុសលជាងយើងទេ ព្រះបាទសាសឺណង់ទូលវិញថា ទូលបង្គំជាខ្ញុំមិនស្មានដូចព្រះអង្គទេ ទូលបង្គំស្មានថាប្រហែលជាយើងទៅមិនឆ្ងាយប៉ុន្មាន គង់បានប្រទះមនុស្សអកុសលមួយមិនខាន លុះ



សន្ទនាដូច្នេះស្រេចហើយក្សត្រទាំងពីរលបចេញពីព្រះរាជវាំងទៅឥតមានឱ្យនរណាដឹង ហើយត្រាច់តាមផ្លូវដទៃផ្សេងពីផ្លូវដែលយាងចូលមកកាត់ព្រៃព្រឹក្សាជរាបដល់ពេលព្រលប់ ក៏ឈប់ផ្ទំក្នុងព្រៃស្ងាត់នោះមួយយប់ លុះអរុណរះឡើងជាថ្មីក៏ទ្រង់រាជដំណើរតទៅទៀត លុះដល់មាត់ឆ្នេរសមុទ្រមានរុក្ខជាតិធំៗ ត្រសុំសាខាប្រកបដោយម្លប់ត្រជាក់ ទ្រង់ក៏សម្រាកព្រះកាយព្វដ៏ទីនោះទាំងពីរព្រះអង្គ ប្រាប់ទុកគ្នាតែអំពីរឿងរាជទេវីចិត្តក្បត់នោះ ។

ទើបតែសម្រាកបានមួយស្របក់ក្នុងទីនោះ ស្រាប់តែឮសព្ទសម្រែកទ្រហឹងរំពងក្នុងកណ្តាលសមុទ្រគួរឱ្យតក់ស្លុត ដោយសម្លេងនោះជាខ្លាំង យូរបន្តិចលេចផុសជាផ្សែងខ្មៅកួចត្របាញ់ពីក្នុងទឹកឡើងខ្ពស់ទៅលើអាកាសវេហាស៍ ក្សត្រទាំងពីរអង្គឃើញដូច្នេះ ក៏រឹតតែភាន់ភាំងស្មារតី ដោយមិនជ្រាបហេតុ ហើយទ្រង់ក៏ស្ទុះស្រវាឡើងលើមែកឈើសំងំពួនទាំងពីរព្រះអង្គ លបមើលទៅឃើញផ្សែងខ្មៅនោះកាន់តែជិតមកៗដល់ត្រើយសមុទ្រ ។

គឺមានអារក្សទឹកមួយដែលជាសត្រូវនឹងមនុស្ស អារក្សនោះខ្លួនខ្មៅ មុខក្រញៀវក្រញូវមាឌធំកម្ពស់ចុងត្នោតលៃ ទូលហឹបកែវមួយលើក្បាល ។ ហឹបនោះមានចាក់សោគ្រប់ ទាំង៤មុមទូលដើរឡើងតាមមាត់សមុទ្រសំដៅមកត្រង់កន្លែងដែល ស្តេចបងប្អូនពួននៅហើយក៏ដាក់ហឹបចុះក្រោមដើមឈើនោះ ។

ឯស្តេចទាំងពីរអង្គមានសេចក្តីតក់ស្លុតស្មើរនឹងបាត់ស្មារតីរំពឹងក្នុងព្រះអង្គថា នឹងដល់នូវសេចក្តីមរណៈហើយ អារក្សដាក់ខ្លួនអង្គុយចុះប្របហឹប ហើយក៏ទាញកូនសោពីចង្កេះចាក់ហឹបនោះ បើកយកស្ត្រីម្នាក់ពីក្នុងហឹបមក ស្ត្រីនោះប្រដាប់កាយដោយគ្រឿងអលង្ការណ៍យ៉ាងឆើតរកអ្វីផ្ទឹមមិនបាន មានរូបឆោមសក្តិសមរាងកាយគួរជាទីសម្រើបដល់បុរសទាំងពួង អារក្សដាក់ស្ត្រីឱ្យអង្គុយជិតខ្លួនហើយថ្នាក់ថ្នមបបោសអង្អែលលួងលោមដោយពាក្យផ្អែមថា "ម្នាលប្អូនសំឡាញ់ដ៏ប្រកបដោយនរលក្ខណ៍ឥតខ្ចោះរបស់បង បងនឹងរកស្ត្រីណាក្នុងលោកនេះមកផ្ទឹមឱ្យប្រហែលនឹងប្អូនគ្មាន តាំងពីបងបានលួចយកប្អូនមកពីកណ្តាលប្រជុំជន ដែលប្អូនកំពុងរៀបអាពាហ៍ពិពាហ៍ ដរាបមកដល់ថ្ងៃនេះ បងឥតមានឃ្លើសចិត្តអ្វីនឹងប្អូនឡើយ បងរឹតតែស្រឡាញ់ច្រើនឡើងៗ វេលានេះសូមប្អូនអនុញ្ញាតឱ្យបងកើយលើភ្លៅបន្តិច ព្រោះបងងងុយដេកណាស់ ថាដូច្នេះហើយក៏ប្រះខ្លួនដេកកើយលើភ្លៅនាងនោះទៅ សណ្តូកជើងស្តូកដល់មាត់សមុទ្រ ហើយស្រមុកខ្ទ័រព្រៃលក់នៅទីនោះ" ។

ឯភរិយាជូនជាងើយមើលទៅចុងឈើ ក៏ប្រទះឃើញក្សត្រទាំង២ ហើយបោយដៃហៅឱ្យលបចុះមក ស្តេចទាំង២ឃើញដូច្នោះក៏ភិតភ័យទ្ទេឡើង សំពះអង្វរពីលើមកថាមិនហ៊ានចុះមកទេ ស្ត្រីនោះរំកិលជើងចេញពីក្បាលអារក្សបានហើយ ក្រោកឈរឡើងកំហែងឱ្យបថា ចុះមកឱ្យឆាប់ហើយចូលមកឯខ្ញុំ ស្តេចទាំងពីរឆ្លើយអង្វរមកវិញថាមិនហ៊ានចុះមកទេ ព្រោះខ្លាចអារក្សណាស់ ។ នាងនោះក៏កំហែងទៅទៀតថា "ចុះមកឱ្យឆាប់ បើខឹរឹងរូស ខ្ញុំនឹងដាស់អារក្សទឹកឱ្យសម្លាប់ឥឡូវ" ។ ស្តេចទាំង២មានសេចក្តីភ័យ តក្កមានឹងអារក្សពេកណាស់ក៏ចុះមក ដោយប្រយ័ត្នថ្នមមិនឱ្យឮសូរឡើយ ក្រែងអារក្សភ្ញាក់ ។ លុះចុះមកដល់ដីវេលាណា ស្ត្រីនោះស្ទុះ ទៅចាប់ទាញដៃទាំងពីរអង្គនាំទៅក្រោមដើមឈើមួយឆ្ងាយពីនោះបន្តិច ហើយបង្ខំឱ្យធ្វើនូវមេថុនកម្ម។ ដើមឡើយក្សត្រទាំងពីរមិនព្រមលុះនាងនោះកំហែងបន្លាចដោយប្រការផ្សេងៗ ទើបធ្វើឱ្យសម្រេចតាមប្រាថ្នាទៅ ។ លុះនាងនោះបានឃើញស្តេចទាំងពីរមានចិញ្ចៀនមួយម្នាក់នៅម្រាមក៏និយាយសុំចិញ្ចៀននោះត្រាតែបាន ហើយទាញយកខ្សែមួយពីក្នុងប្រអប់ដែលដាក់ក្នុងអាវចេញមក។ នៅខ្សែនោះមានចិញ្ចៀនឯទៀតជាច្រើនបែបនាងនោះសួរទៅស្តេចបងប្អូនថា "អ្នកបានដឹងរឿងចិញ្ចៀនទាំងនេះឬទេ? ស្តេចទាំងពីរឆ្លើយតបថា យើងមិនដឹងរឿងអ្វីទេ សូមឱ្យនាងអធិប្បាយប្រាប់យើងឱ្យដឹងចុះ នាងក៏ប្រាប់ថា ចិញ្ចៀនទាំងនេះសុទ្ធតែជារបស់ប្រុសដែលបានធ្វើសេវនកិច្ចជាមួយនឹងខ្ញុំ គឺចិញ្ចៀនមួយប្រុសមួយ ទាំងអស់បានចិញ្ចៀន ៩៨ ហើយខ្ញុំបានសុំមកទុកជាទីរលឹករបស់ខ្ញុំ ដែលខ្ញុំសុំរបស់អ្នកនេះ ដើម្បីយកមកទុកជាទីរលឹកដូច្នេះដែរ បំពេញឱ្យបានគ្រប់ ១០០" ។ តាំងពីអារក្សយកខ្ញុំមកទល់

នឹងថ្ងៃនេះ ខ្ញុំមានសហាយ ១០០នាក់ ហើយៗ អារក្សនេះប្រយ័ត្នខ្ញុំជាទីបំផុត មិនដែលឃ្លាតទៅទីឯណាឆ្ងាយចោលខ្ញុំទេ ដូចអ្នកឃើញច្បាស់នឹងភ្នែកស្រាប់ វាទុកខ្ញុំតែក្នុងហឹប លាក់ដល់បាតសមុទ្រប្រយ័ត្នយ៉ាងនេះ ខ្ញុំគង់តែផិតវាបាន ត្រូវឱ្យអ្នកដឹងប្រាកដថា តែកាលណាស្ត្រីផ្ទៀងចិត្តទៅលើអ្វីហើយគ្មានប្ដីណាឬសហាយណាទៅការពារទប់ឈ្នះឡើយ ជាតិប្រុសត្រូវកុំខាខាំងឬបង្ខំចិត្តស្រី ត្រូវបណ្ដោយតាមការវិញល្អជាង ។ សេចក្ដីដែលបើកបណ្ដោយនេះហើយជាឧបាយដ៏សំខាន់ដើម្បីឱ្យស្ត្រីដើរត្រឹមត្រូវតាមគន្លងស្រី ប្រាប់តែប៉ុណ្ណោះ ក៏យកខ្សែដោតចិញ្ចៀនទាំងពីរបញ្ចូល ជាមួយគ្នានឹងចិញ្ចៀនមុនៗ ទើបដើរចូលទៅអង្គុយជិតប្ដីលើកក្បាល ដាក់ឱ្យកើយលើភ្លៅដូចដើមវិញ បក់ដៃឱ្យស្ដេចទាំងពីរគេចខ្លួនទៅ ។

ឯស្ដេចបងប្អូនក៏ដើរតាមផ្លូវដដែល ឆ្ពោះទៅនគរវិញ។ លុះដើរឆ្ងាយបន្តិចពីទីនោះទៅ ល្មមមើលផុតកន្ទុយភ្នែក ស៊ុលតង់សារ្យាមានបន្ទូលទៅនឹងអនុជថា "នែប្អូន ! អ្នកយល់ដូចម្ដេចរឿងអម្បាញ់មិញនេះ តើអារក្សនោះវាគិតស្មានថាខ្លួនវាមានភរិយាស្លូតត្រង់តាមគន្លងធម៌ឬទេ? ប្អូនជឿជាក់ថាគ្មានអ្វីស្មើនឹងពុតស្ត្រីដែរឬទេ?" វេលានោះ ព្រះអនុជទូលតបវិញថា "ទូលបង្គំជាខ្ញុំជឿប្រាកដដូច្នេះណាស់ សូមឱ្យព្រះអង្គសន្និដ្ឋានថា អារក្សនោះគួរថ្ងូញគួរថ្ងូរច្រើនជាងយើងទាំងពីរនាក់ ព្រោះខ្លួនវាជាអ្នកឥតភ័ព្វជាអ្នកអកុសលជាងយើងច្រើនណាស់ បើដូច្នេះគួរយើងវិលទៅកាន់នគរយើងវិញ ព្រោះយើងបាន



ឃើញហេតុដែលយើងដើរនេះហើយ យើងត្រូវយល់ថាគ្មានអ្វីឃាត់ខាំងមិនឱ្យយើងយកភរិយាទៀត ។ ចំណែកទូលបង្គំជាខ្ញុំនោះ នឹងធ្វើតាមគំនិតដែលបានគិតទុកស្រេចយូរហើយក្នុងរឿងនេះ គំនិតនោះព្រះអង្គគង់នឹងជ្រាបទៅថ្ងៃក្រោយ ទូលបង្គំប្រាកដក្នុងចិត្តថាវេលាណាព្រះអង្គបានជ្រាបព្រះអង្គមុខជានឹងធ្វើតាមទូលបង្គំមិនខាន ស៊ុល-តង់សារ្យា ក៏ព្រមតាមព្រះអនុជក្នុងវេលានោះ ហើយស្ដេចត្រឡប់ទាំងពីរអង្គ ឆ្ពោះទៅព្រះពន្លាដែលអគ្គមហាសេនានៅចាំក្នុងព្រៃស្ដេចទាំងពីរ យាងទៅដល់វេលាព្រលប់នៅថ្ងៃទី៣ គឺថ្ងៃដែលទ្រង់ចេញទៅពីព្រះពន្លានោះ ។

ឯអគ្គមហាសេនានឹងអាមាត្យទាំងឡាយ ដែលនៅក្នុងទីនោះ លុះបានដឹងថាស្ដេចទាំងពីរយាងចូលមកវិញហើយ ក៏ព្រមព្រៀងជួបជុំគ្នាចូលទៅថ្វាយបង្គំគាល់ទាំងពីរព្រះអង្គទទួលដោយសេចក្ដីករុណា លុះសាកសួរកិច្ចការផ្សេងៗស្រេចហើយ ទើបត្រាស់បង្គាប់ទៅអគ្គ-មហាសេនាឱ្យរៀបភ្នំរេហ៍ពល ត្រឡប់ចូលទៅព្រះបរមរាជវាំងវិញ ព្រោះព្រះអង្គមិនចង់នៅក្រសាលតទៅឡើយហើយក៏ទ្រង់ឡើង អា-ជានេយ្យសីហនាទចូលដល់ព្រះរាជវាំងក្នុងរាត្រីនោះ ។

**ចប់ភាគទី១ តែប៉ុណ្ណេះ**

**រឿងក្នុងភាគទី២ កាន់តែចម្លែកណាស់ទៅទៀត**

**សូមអញ្ជើញមើលតទៅកុំខាន ។**

# ឯកសហស្សរាត្រី

# ឬមួយពាន់មួយយប់

## (ភាគទី២)

លុះយាងចូលទៅក្នុងព្រះរាជដំណាក់ វេលាណាស្តេចសារ្យា ក៏ស្ទុះចូលទៅក្នុងបន្ទប់ព្រះអគ្គមហេសី ហើយទ្រង់ព្រះបញ្ជាឱ្យចាប់នាងចង ប្រគល់ដល់ដៃអគ្គមហាសេនាឱ្យយកទៅប្រហារជីវិតបង់ក្នុងវេលានោះ ឥតប្រាប់ឱ្យដឹងរឿងដែលខុសឆ្គងអ្វីសោះ ។

អគ្គមហាសេនា ក៏ទទួលព្រះរាជអាជ្ញាទៅសម្រេចឃាតកម្មទៅ រីព្រះមហាក្សត្រ ដោយទ្រង់ព្រះពិរោធខ្លាំងក៏ចាប់ព្រះសែងថ្លាប្រហារនូវស្ត្រីទាំងប៉ុន្មាន ដែលជាស្រីស្នំក្រមការព្រះអគ្គមហេសីដោយព្រះហស្តព្រះអង្គឯង លុះផ្តន្ទាទោសរួចហើយ ទ្រង់ឈ្វេងយល់ថា: អំណើះតទៅនឹងជ្រើសរើសរកស្ត្រីម្នាក់ឱ្យបានត្រឹមត្រូវតាមគន្លង-ធម៌គ្មាន ទើបទ្រង់ព្រះតំរិះថា នឹងយកស្ត្រីមករួមសង្វាសតែមួយយប់ម្នាក់ រួចយកទៅប្រហារជីវិតបង់នៅក្នុងវេលាព្រឹកឡើង ដល់បានកម្រិតព្រះរាជកំណត់ច្បាស់ជាស្រេចដូច្នោះហើយ ទ្រង់ប្តេជ្ញាថា នឹងចាប់ធ្វើនៅវេលាដែលព្រះអនុជាធិរាជត្រឡប់ទៅនគរវិញ ឯស្តេចសាសីណង់មិនបានគង់នៅយូរប៉ុន្មាន ក៏លាព្រះជេដ្ឋាវិលត្រឡប់ទៅ

ក្រុងសាមារក័ណ្ឌដោយរួសរាន់ នាំគ្រឿងបណ្ណាការជាដង្វាយដែលព្រះរៀម ព្រះរាជទានទៅជាមួយផង ។

លុះស្តេចសាសីណង់យាងចេញផុតទៅ សុលតង់សារ្យាទ្រង់បង្គាប់អគ្គមហាសេនាឱ្យនាំស្ត្រីម្នាក់ ដែលជាកូនសេនាទាហានសក្តិខ្ពស់ម្នាក់មកថ្វាយទ្រង់រួមប្រវេណី នឹងស្ត្រីនោះតែមួយយប់ដល់វេលាព្រឹកឡើងឱ្យយកទៅប្រហារជីវិតបង់ ហើយក្នុងយប់ក្រោយឱ្យយកម្នាក់មកថ្វាយទៀត។ អគ្គមហាសេនាដោយខ្លាចស៊ុលត្រង់ណាស់ ក៏ទទួលស្តាប់ហើយធ្វើតាមទៅ លុះយប់ក្រោយនាំយកបុត្រីសេនាទាហានជាន់ទាបទៅថ្វាយ ហើយព្រឹកស្អែកឱ្យយកទៅសម្លាប់ចោលទៀត រួចពីនោះមកដល់វេនស្ត្រីដែលជាកូនរាស្ត្រអ្នកមានមុខនៅក្នុងក្រុង ស្តេចឱ្យយកទៅប្រហារជីវិតគ្រប់តែស្ត្រីឥតមានលោះមួយណាឡើយ ។

ដំណឹងនេះ មិនបាត់ស្ងាត់ក៏បែកសាយទូទៅពេញទាំងក្រុងឮសូរស័ព្ទសម្រែកនឹងស័ព្ទឭញថ្ងូរទ្រហឹងអឹងកង ជួនកាលឃើញឪពុកស្រែកទ្រហោយំបោកខ្លួនប្រាណដោយស្តាយកូន ដែលគេសម្លាប់ ជួន-កាលឮសូរសេចក្តីត្អូញថ្ងូររបស់ម្តាយ ដែលមានកូនស្រីភិតភ័យក្រែងកូនត្រូវព្រះរាជអាជ្ញាដែរ តាំងអំពីដើមរៀងមកបណ្តារាស្ត្រតែងពោលសរសើរថ្វាយសាធុការពរ ដល់ស៊ុលតង់គ្រប់កន្លែងចាប់ដើមពីនោះមក ឮតែសម្លេងប្រទេចផ្តាសាដល់ស្តេចនោះវិញ ។



អគ្គមហាសេនាមានបុត្រី ២នាក់ នាងបងឈ្មោះ សែរ៉ាសាដ[១] ឯនាងប្អូនឈ្មោះឌីណារសាដ[២] ធីតាទាំងពីរនេះមានរូបឆោមល្អដូចគ្នា ប៉ុន្តែនាងបងមានសេចក្តីក្លាហានជាង ហើយប្រកបដោយសតិបញ្ញាឆ្លៀវឆ្លាសហួសភេទជាស្ត្រីភាព ប្រកបដោយសេចក្តីឧស្សាហ៍ព្យាយាមរៀនសូត្រក្បួនខ្នាតជាច្រើន ហើយចាំអស់រឿងរ៉ាវដែលបានមើលទាំងប៉ុន្មាន នាងបានសិក្សាសព្វវិជ្ជាផ្សេងៗ មានក្បួនវិជ្ជាសារពើដែលឥតរូបវិជ្ជាពេទ្យ ពង្សាវតារ នឹងក្បាច់រចនាជាដើម។ ចំណែកខាងកាព្យឃ្លោងក៏ប៉ិនប្រសប់ចំណាន ដូចជាពួកកវីយ៉ាងពូកែក្នុងជាន់នោះក្រៅពិនេះ នាងមានរូបឆោមលោមពណ៌ប្រកបដោយនរលក្ខណ៍គ្រប់ប្រការទាំងឫកពាមារយាទក៏ត្រឹមត្រូវតាមបែបបទឥតឆ្គង ។ បិតាស្រឡាញ់បុត្រីពន់ពេកណាស់ មានកាលសម័យមួយកំពុងតែអង្គុយនិយាយគ្នាលេងនាងនិយាយទៅកាន់អាពុកថាបពិត្របិតាខ្ញុំមានប្រាថ្នា នឹងសុំអនុញ្ញាតធ្វើកិច្ចមួយ សូមឱ្យលោកអាពុកអនុញ្ញាតឱ្យនាងខ្ញុំកុំខាន ។ វេលានោះអគ្គមហាសេនាឆ្លើយតបទៅវិញថា អាពុកឥតរាំងដល់សេចក្តីប្រាថ្នារបស់កូនទេ បើសេចក្តីអនុញ្ញាតដែលកូនសុំនោះ ត្រឹមត្រូវតាមគន្លងច្បាប់ល្មមអាពុកបើកឱ្យបាននាងឆ្លើយថា ដែលលោកពុកថាឱ្យ

១- សែរ៉ាសាដ ជាពាក្យអារ៉ាប់ប្រែថា "កូនព្រះចន្ទ្រ" ពាក្យនេះ សរសេរជាអក្សរខ្មែរមិនចំទេ ។

២- ឌីណារសាដ ប្រែថា "ល្អដូចមាស" ដាក់ជាអក្សរខ្មែរមិនចំដូចគ្នា ។

ត្រឹមត្រូវតាមគន្លងធម៌នោះ ខ្ញុំយល់ឃើញថាមិនជាត្រូវពេញប៉ុន្មាន តែថាលោកអាពុកអាចនឹងសន្និដ្ឋានពិចារណាទៅបានតាមទំនងហេតុ ដែលបណ្ដាលឱ្យខ្ញុំសុំនេះ គឺខ្ញុំមានបំណងនឹងបំបាត់នូវអំពើបាប ដែលមហាក្សត្រតែងប្រព្រឹត្តលើត្រកូលនីមួយៗក្នុងក្រុងនេះ គឺខ្ញុំមានបំណងនឹងបំបាត់នូវសេចក្ដីភិតភ័យតក់ស្លុតសេចក្ដីត្អូញ ថ្ងូររបស់មនុស្សដែលមានបុត្រីទាំងប៉ុន្មាន កុំឱ្យមានទៅទៀត វេលានោះអគ្គមហារសេនាតបទៅវិញថា ម្នាលកូន ! សម្ដីដែលកូនពោលមកនេះពេញជាមហាប្រសើរហើយ តែថារោគដែលកូនចង់យកឱសថ ទៅដាក់នេះអាពុកស្មានថាហាក់ដូចជាគ្មានថ្នាំណាទប់ទល់ការពារបានឡើយ បើដូច្នេះតើកូនគិតដូចម្ដេចឱ្យបានសម្រេចតាមសេចក្ដីប្រាថ្នានាងឆ្លើយទៅវិញថា រាល់តែយប់លោកអាពុកនាំស្ត្រីម្នាក់ៗទៅថ្វាយស្ដេច សេចក្ដីនេះខ្ញុំអង្វរសូមឱ្យលោកអាពុកនាំខ្លួនខ្ញុំទៅថ្វាយស្ដេចចុះ កាលបានស្ដាប់ពាក្យគួរស្ញើម គួរខ្លាចរបស់កូនដូច្នេះហើយ អគ្គមហាសេនាក៏ស្រែកកាត់ដោយសេចក្ដីក្រោធថា "ឱម្ចាស់ថ្លៃអើយ ! ជួយស្ដាប់ខ្ញុំមើលចុះ កូនឯងវលត់សតិហើយឬអីបានជាហ៊ាននិយាយសុំគ្រោះអាក្រក់មកដាក់ខ្លួនដូច្នេះចុះ កូនមិនដឹងទេឬ? ស្ដេចបានប្ដេជ្ញាថានឹងផ្ទំជាមួយនឹងស្រីម្នាក់តែមួយយប់ហើយយកទៅកាប់សម្លាប់ មិនដែលបណ្ដោយឱ្យហួសកំណត់ ម្ដេចក៏បានជាចង់ឱ្យអាពុកនាំកូនទៅថ្វាយស្ដេចដូច្នោះកូនគិតឱ្យសព្វទៅមើល បើទុកជាកូនចេះផ្ដាប់ ត្រូវបែបបទយ៉ាងណា



ក៏ជាការឥតប្រយោជន៍នឹងខាខាំងឱ្យឈ្នះ សេចក្ដីប្ដេជ្ញារបស់ស្ដេចមិនបានឡើយ" នាងឆ្លើយតបទៅវិញថា "ខ្ញុំបានដឹងច្បាស់ហើយគ្រោះកាចទាំងនោះ ប៉ុន្តែខ្ញុំឥតរំភើបអ្វីនឹងគ្រោះទាំងនោះទេ បើជាខ្ញុំស្លាប់ក៏សេចក្ដីស្លាប់របស់ខ្ញុំនោះជាមង្គលប្រសើរដែរ" បើប្រសិនជាខ្ញុំធ្វើទៅហើយបានសម្រេចដូចសេចក្ដីប្រាថ្នាវិញ ខ្ញុំនឹងមានគុណបំណាច់យ៉ាងធំលើព្រះនគរ ។ អគ្គមហាសេនាឆ្លើយតបទៅវិញថា "ទេៗកូនកុំថាដូច្នោះ បើទុកជាកូនចេះថាដូចម្ដេចទៀត ដើម្បីឱ្យអាពុកព្រមនាំកូនទៅចូលក្នុងសេចក្ដីវិនាសនោះ ក៏កុំឱ្យគិតស្មានថា អាពុកនឹងអនុញ្ញាតឱ្យសោះឡើយ កាលណាបើស្ដេចប្រើអាពុកឱ្យនាំកូនយកទៅសម្លាប់នោះឱ្យអាពុកធ្វើម្ដេច គឺត្រូវតែអាពុកទទួលតាមព្រះរាជអាជ្ញាខានមិនបានចូរកូនរំពឹងគិតឱ្យជ្រៅទៅមើល កាលដែលអាពុកយកអាវុធទៅសម្លាប់កូនខ្លួននោះគួរឬ? ឱកូន ! បើកូនមិនខ្លាចស្លាប់ក៏ហើយទៅចុះតែត្រូវឱ្យកូនខ្លាចថា ហេតុនេះ នឹងនាំឱ្យអាពុកមានទុក្ខដល់ស្លាប់ខ្លួនវិញ នៅវេលាដែលអាពុកឃើញដៃប្រឡាក់ដោយឈាមកូនឯង នាងឆ្លើយតបវិញថា "ខ្ញុំសូមអង្វរលោកអាពុកម្ដងទៀត សូមឱ្យអនុញ្ញាតឱ្យខ្ញុំកុំខាន" អគ្គមហាសេនានិយាយ តឹងសម្លេងឡើងថាសេចក្ដីចចេសរបស់ឯងនាំឱ្យអញខឹងជាខ្លាំង ចុះហេតុអ្វីបានជានៅសុខមិនចង់ទៅចង់ស្លាប់វិញ នរណាក៏ដោយ បើមិនបានពិចារណាឱ្យជ្រៅក្នុងការអន្តរាយនឹងអាចដកខ្លួនឱ្យផុតមិនបាន ទាំងនេះសុទ្ធតែឥត

ប្រយោជន៍សោះហើយ និងមានគ្រោះអាក្រក់ដល់ខ្លួនផង អញក្រែងខ្លួនឯងនេះដូចជារឿងសត្វលាមួយ ដែលចង់ឱ្យគេបានសុខស្រួល ទៅជាបានទុក្ខមកលើខ្លួនវិញ ។ នាងសួរថា តើទុក្ខដែលធ្លាក់លើខ្លួនសត្វលានោះដូចម្តេចខ្លះ? អគ្គមហាសេនាឆ្លើយប្រាប់ថា ឯរឿងលានេះចូរឯងប្រុងស្តាប់ចុះ... ។

## រឿងសត្វលា១ សត្វគោ១ និងអ្នកភ្ជួរស្រែម្នាក់

មាននាយពាណិជម្នាក់ ប្រកបដោយភោគសម្បទបានសង់ផ្ទះជាច្រើនខ្នងនៅស្រុកស្រែ ហើយបានចិញ្ចឹមសត្វស្រុកជាច្រើន មានសម័យមួយ នាយពាណិជបាននាំប្រពន្ធកូនទៅត្រួតមើលស្រូវអង្ករនៅទីផ្ទះមួយ ឯនាយពាណិជមានវិជ្ជាមួយដ៏សំខាន់ គឺចេះស្តាប់ភាសាសត្វទាំងអស់ ប៉ុន្តែស្តាប់បានតែម្នាក់ឯង និងនិយាយប្រាប់អ្នកដទៃមិនបានតែនិយាយទៅនឹងមានអន្តរាយដល់ជីវិតខ្លួន ។

នៅទីក្រោលមួយ គេតែងដាក់សត្វលា និងគោជាមួយគ្នា ។ ថ្ងៃមួយ វេលាដែលនាយពាណិជកំពុងតែអង្គុយលេងប្របក្រោលនោះ ដើម្បីមើលកូនតូចៗ ដែលលេងជាមួយគ្នា ស្រាប់តែឮគោនិយាយទៅលាថា ម្នាលបងលាជាសត្វឥតទុក្ខ សព្វថ្ងៃនេះ តាមខ្ញុំរំពឹងមើលទៅឃើញថា បងឯងពេញជាមានភ័ព្វមហាស្រណុក ព្រោះគេឱ្យបងឯងធ្វើការតិចណាស់ មានមនុស្សថែទាំបងឯង ហើយដុសលាងសំអាត





ជានិច្ច ឱ្យស៊ីសុទ្ធតែស្រូវយ៉ាងស្អាតគ្មានសំដីមួយគ្រាប់លាយសោះ នឹងឱ្យផឹកតែទឹកយ៉ាងថ្លាត្រជាក់ ។ ការនឿយបំផុតរបស់បងឯងនោះ គឺគ្រាន់តែឱ្យម្ចាស់ជិះបន្តិចៗប៉ុណ្ណោះវេលាដែលគាត់មានដំណើរទៅណាមកណា ហើយបើម្ចាស់មិនត្រូវការទេ បងឯងនៅសម្រាន្តជាសុខឥតព្រួយបារម្ភអ្វីសោះ។ ឯចំណែកមុខងាររបស់ខ្ញុំវិញ ឃើញប្លែកគ្នាពន់ពេក ពេលវេលាខ្ញុំក៏ខុសគ្នាពីបងឯងឆ្ងាយទូលាយណាស់មិនទាន់រំលងអធ្រាត្រទៅប៉ុន្មាន គេយកខ្ញុំទៅបញ្ចូលនឹមនង្គ័ល ហើយបរទៅភ្ជួររាស់ដីទាំងយប់នោះ លុះព្រឹកឡើងទាល់ល្ងាចទៅទៀត ឥតឱ្យឈប់ឈរសម្រាកកម្លាំង ខ្ញុំហត់ស្ទើរតែនឹងដាច់ខ្យល់ ឯអ្នកភ្ជួរដែលនៅក្បែរតូចជានិច្ច មិនបង្អង់វាយតូចខ្ញុំឡើយ ដោយខ្ញុំប្រឹងទាញនង្គ័លរនាស់ខ្លាំងណាស់ទៅ ស្បែកកខ្ញុំក៏របកទាំងដុំៗ។ ដល់ព្រលប់ខ្ញុំត្រឡប់ចូលមកក្រោលវិញ គេយកចំបើងដោយទាំងដីធ្លី សំរាមសំរោចមកឱ្យខ្ញុំស៊ី ខ្ញុំក៏អត់ធ្មត់ខំប្រឹងស៊ីគ្រាតែឆ្អែតទៅ ហើយត្រូវប្រះខ្លួនដេកលើអាចម៍លើនោមខ្ញុំជានិច្ច ព្រោះគ្មានកន្លែងផ្សេងសម្រាប់ដេក បើដូច្នេះ តើខ្ញុំច្រណែននឹងភ័ព្វសំណាងបងឯងគួរឬទេ ?

វេលានោះ សត្វលាមិនឆ្លើយកាត់គោថា ដូចម្ដេច? បណ្ដោយឱ្យគោនិយាយលុះអស់សេចក្ដីទើបលាឆ្លើយតបទៅថា “ម្នាលគោ ពាក្យដែលឯងនិយាយតូញត្អែរទាំងប៉ុន្មាន សុទ្ធតែពិតទាំងអស់ឥតមានបំភ្លើសឡើយ ប៉ុន្តែបានជាដូច្នេះ ព្រោះឯងឆ្កួតខ្លួនឯង នឹងបន្ទោស



អ្នកឯណា ក៏មិនបានឯងធ្វើស្លូតពេក បណ្ដោយឱ្យគេដឹកនាំទៅតាមត្រូវការឥតមានរឹងរូសអ្វីបន្តិចសោះ ដែលឯងនឿយព្រួយលំបាកទាំងម៉្លេះ តើឯងបានប្រយោជន៍អ្វីខ្លះដែរឬទេ? ឯងខំប្រឹងធ្វើការស្ទើរស្លាប់ខ្លួន ដើម្បីប្រយោជន៍ដល់មនុស្សដែលគ្មានគិតដល់សេចក្ដីនឿយហត់របស់ឯងសោះ ប្រសិនបើឯងមានសេចក្ដីក្លាហានស្មើនឹងកម្លាំងរបស់ឯង នោះគេមិនអាចធ្វើឯងដូច្នេះឡើយ ហេតុអ្វីបានជាវេលាដែលគេដឹកឯងទៅបញ្ចូលនឹមឯងមិនទំរន់កុំទៅដោយស្រួលហើយឯងមិនស្ទុះទៅគំរាមនឹងស្នែងរបស់ឯងធ្វើជាខឹងតន្ត្រំដី? ហេតុអ្វីបានជាមិនស្រែករោទ៍ឱ្យលាន់លឺខ្លាំងឡើង? អញឃើញថាឯងមានគ្រឿងបង្ការគ្រប់គ្រាន់ល្មមធ្វើឱ្យគេខ្លាចបាន ប៉ុន្តែឯងមិនប្រើប្រដាប់នោះសោះ កាលណាបើគេយកស្មៅស្ងួតមកឱ្យស៊ីត្រូវឯងកុំស៊ីគ្រាន់តែហិតៗ ហើយដើរចេញទៅ បើឯងតាមដំបូន្មានអញនេះ ឯងនឹងបានសុខស្រួលមិនខាន ហើយឯងនឹងអរគុណដល់អញមិនលែងឡើយ” ។

វេលានោះ គោទទួលយកដំបូន្មាន អរគុណនឹងសត្វលាជាអនេកប្រការ ហើយមានវាចាថា ចាប់ផ្ដើមតាំងពីថ្ងៃនេះទៅ ខ្ញុំនឹងធ្វើតាមពាក្យប្រដៅរបស់បងឯងមិនខាន ឱ្យបងឯងចាំមើលខ្ញុំចុះ ។ គោនិងលានិយាយគ្នាតែប៉ុណ្ណេះក៏ស្ងៀមទៅ ។ ឯនាយពាណិជ្ជបានស្ដាប់សត្វទាំងពីរចាំឥតមានភ្លេចមួយម៉ាត់ ។

លុះព្រឹកឡើង អ្នកភ្ជួរស្រែភ្ញាក់ពីព្រលឹមដឹកគោយកទៅទឹម

តាមធម្មតា ឯគោដែលចាំដំបូន្មានលាជានិច្ច ក៏ធ្វើកាចក្នុងថ្ងៃនោះយ៉ាងគ្រាន់បើ ដល់ពេលព្រលប់វេលាដែលគេយកទៅបញ្ចូលក្រោលហើយយកខ្សែទៅចង ក៏មិនបណ្ដោយឱ្យចងតាមទម្លាប់ប្រឹង ត្រវីស្នែងស្រែករោទ៍កញ្ជ្រោលស្ទុះថយក្រោយ ហើយបន្ទាបក្បាលចុះធ្វើអាការៈចង់បុះអ្នកនោះ តាមពាក្យដែលសត្វលាបញ្ចេះទាំងអស់ លុះព្រឹកស្អែកឡើងទៀត អ្នកភ្ជួរស្រែក៏ទៅពីព្រលឹម ដើម្បីនាំយកទៅទឹមទៀត វេលាដែលដើរទៅដល់ឃើញចំបើងដែលដាក់ឱ្យស៊ីពីល្ងាចសល់នៅទាំងអស់ ហើយឃើញគោដេកជើងត្រង់ស្ដូក ដកង្ហើម ដង្ហក់មិនដូចប្រក្រតី ក៏ស្មានថាជាគោមានជំងឺ អ្នកភ្ជួរស្រែអាណិតគោណាស់ ក៏ខាននាំទៅទឹម ទើបយកសេចក្ដីទៅជម្រាបដល់នាយពាណិជថាគោឈឺ ។

នាយពាណិជកាលបានឮដូច្នោះហើយក៏យល់ឃើញថា គោនោះធ្វើតាមពាក្យដែលសត្វលាបញ្ចេះពិត ។ ដើម្បីនឹងដាក់ទណ្ឌកម្មដល់សត្វលា ក៏ប្រាប់ទៅអ្នកភ្ជួរស្រែថា “អឺ បើគោឈឺ ត្រូវឯងយកលាទៅទឹមជាជំនួសវិញ បើទឹមហើយត្រូវឯងប្រើវាឱ្យនឿយ ធ្វើឱ្យលំបាកយ៉ាងច្រើន កុំប្រណីឡើយ” អ្នកភ្ជួរទទួលបង្គាប់ ហើយនាំយកលាទៅទឹមជំនួសក្នុងថ្ងៃនោះ ឯសត្វលាក៏សោយទុក្ខវេទនាពន់ប្រមាណ ដោយខ្លួនមិនធ្លាប់ធ្វើការដូច្នេះផង នឹងដោយគេវាយឥតត្រាប្រណីផង ។



ឯចំណែកគោក៏បានសេចក្ដីសុខស្រួល នៅថ្ងៃនោះមហិមាស៊ីស្មៅទាំងប៉ុន្មានដែលគេបានដាក់ឱ្យ ហើយដេកសម្រាកកំលាំងតាំងពីព្រលឹមដល់ព្រលប់ ទើបរំពឹងក្នុងចិត្តថា “អញធ្វើតាមពាក្យប្រដៅរបស់លាទៅ ឃើញស្រួលមែនហើយ ក៏ឱ្យពរដល់លាជាច្រើន” ។ លុះឃើញលាត្រឡប់មកពីស្រែវិញក៏និយាយសរសើរ នឹងអរគុណ តែវេលានោះលាមិនចេញស្ដីមួយម៉ាត់ ដោយតូចចិត្តខ្លាំងអំពីគេប្រើហើយធ្វើបាបពេញមួយថ្ងៃ ។ លាគិតតែក្នុងចិត្តថា “ការនេះ មកពីអញមិនបានគិតឱ្យជ្រៅម្យ៉ាង និងមកពីអញធ្វេសប្រហែសម្យ៉ាងបានជាអកុសលធ្លាក់លើខ្លួនអញដូច្នេះ កាលពីដើមខ្លួនអញបានសុខស្រួលសប្បាយ ជាទីបំផុត ចង់ធ្វើដូចម្ដេចក៏បានតាមចិត្តអញទាំងអស់ ឥឡូវមកពីកំហុសរបស់អញបានជាអញធ្លាក់ខ្លួនដល់ទីនេះ បើនៅស្ងៀមមិនគិតរកឧបាយអ្វីកែខ្លួនទេ អញមុខជាខូចការធំមិនខាន” គិតដូច្នេះ ហើយក៏ផ្ដួលខ្លួនដេកដូចជាស្លាប់ក្បែរស្នាចស្រូវនោះទៅ ព្រោះអស់កម្លាំងស្ទើរនឹងផុតដង្ហើម ដោយខំទាញនង្គ័លតាំងពីព្រលឹម លុះពេលព្រលប់ ។

អគ្គមហាសេនានិយាយដល់សេចក្ដីត្រង់នេះ ក៏បែរទៅប្រាប់នាងសែហ៊្រាសាដថាៈ “នែកូន ! គំនិតកូនឯងដូចសត្វលាដូច្នោះ គឺសេចក្ដីចំណង់របស់កូនឯងនាំឱ្យអន្តរាយខ្លួន” ដោយមិនបានគិតឱ្យជ្រៅបុរាណថា “កុំឱ្យយកកទៅលអន្ទាក់ ចូរកូនជឿអាពុកចុះ នៅផ្ទះឱ្យស្ងៀមទៅកុំរករឿងចង់ស្លាប់ដូចគេ” ។ នាងឆ្លើយតបថា “លោកអាពុក

រឿងដែលលោកអាពុកយកមកធ្វើជាឧទាហរណ៍ពន្យល់ខ្ញុំនោះ មិនអាចនឹងទប់ទល់សេចក្ដីប្រាថ្នារបស់ខ្ញុំ ឱ្យប្រែប្រួលទៅទៀតបានឡើយ កាលណាបើលោកអាពុកព្រមនាំខ្ញុំទៅថ្វាយស្ដេច ទើបខ្ញុំសុខចិត្តលែងរំអុកលោកអាពុកទៅទៀត" ។ អគ្គមហាសេនាលុះឃើញបុត្រីចចេសទទូចសុំដូច្នោះ ក៏ប្រាប់ទៅទៀតថា "អើបើឯងមិនព្រមផ្លាស់គំនិតអាក្រក់នេះចេញទេ ត្រូវអញធ្វើឯងបន្តិចឱ្យដូចជានាយពាណិជធ្វើបំបាត់ចំណង់ប្រពន្ធនៅខាងចុងរឿង ដែលនិទានអម្បាញ់មិញនេះ ចូរឯងប្រុងស្ដាប់ចុះ" អគ្គមហាសេនាចាប់រឿងទៅទៀតថា :

ឯនាយពាណិជកាលបានដឹងថាលា មានសេចក្ដីទុក្ខវេទនាខ្លាំងដូច្នោះហើយ ក៏នឹកចង់ដឹងរឿងលានឹងគោ តើវានិយាយគ្នាដូចម្ដេចទៀត លុះរួចបាយល្ងាចហើយ នាយពាណិជនាំប្រពន្ធកូនដើរទៅលេងក្នុងវេលាយប់ខែភ្លឺច្បាស់ ក៏ទៅឈរជិតក្រោលសត្វនោះស្រាប់តែឮលាសួរទៅគោថា "ម្នាលគោសំឡាញ់អើយ ! ឯងនឹងគិតធ្វើដូចម្ដេចទៅទៀតដល់គេយកស្មៅមកឱ្យឯងស៊ីព្រឹកស្អែកនេះ? គោឆ្លើយតបថា ខ្ញុំនឹងធ្វើដូចជាបងឯងប្រដៅពីម្សិលមិញដូច្នោះទៀត ដំបូងខ្ញុំត្រូវថយឱ្យឆ្ងាយរួចខ្ញុំគ្រវីស្នែងចូល ខ្ញុំធ្វើពុតជាឈឺ ហើយស្រែករោទិ៍ឱ្យឮខ្លាំងឡើង" វេលានោះលាឆ្លើយកាត់ថា : "នែសំឡាញ់ការនេះឃើញជាមិនស្រួលទេអញហាមឯងឱ្យហើយ ចូរឯងស្ដាប់អញ ត្រូវឯងកុំធ្វើដូច្នោះទៀត តែខំធ្វើនឹងអន្តរាយដល់ខ្លួនមិនខាន ព្រោះវេលាដែល



អញដើរមកចូលក្រោល ដល់កណ្ដាលផ្លូវអញឮម្ចាស់ យើងនិយាយការមួយ អញស្ដាប់ហើយភ័យតក់ស្លុតរន្ធត់ជួសឯងណាស់" គោសួរថា "បងឯងឮដូចម្ដេច? កុំលាក់នឹងខ្ញុំអាណិតប្រាប់ខ្ញុំផង" លាឆ្លើយប្រាប់ថា "អញបានឮម្ចាស់យើងនិយាយនឹងអ្នកភ្ជួរថា បើគោវាឈឺមិនស៊ីស្មៅហើយក្រោកមិនរួចដូច្នោះ វេលាព្រឹកស្អែកត្រូវឯង យកទៅសម្លាប់ហើយចែកចាយសាច់ដល់អ្នកកំសត់ទុគ៌តទៅ ឯស្បែកវាដែលមានប្រយោជន៍នោះ ត្រូវឯងប្រគល់ឱ្យទៅជាងសម្លាប់ស្បែក ត្រូវឯងទៅហៅអ្នកពិឃាតសត្វមកកុំខាន" លាប្រាប់បន្ថែមទៅគោទៀតថា "ដែលអញបានឮមកគឺយ៉ាងនេះ ហើយអញមិនចង់ឱ្យឯង អន្តរាយជីវិតព្រោះអញអាណិតស្រឡាញ់ឯងបានជាអញមកប្រាប់ ឯងវេលាព្រឹកស្អែកឡើង បើគេយកស្មៅមកឱ្យ ត្រូវឯងក្រោកឡើងយ៉ាងរហ័សហើយស្ទុះទៅរកស្មៅនោះ ធ្វើដូច្នេះម្ចាស់យើងនឹងសម្គាល់ឃើញថាឯងជាពិតប្រាកដ ហើយគាត់ក៏លែងឱ្យសម្លាប់ទៅវិញ អញប្រាប់ឯងតែប៉ុណ្ណេះ បើឯងធ្វើខុសពីនេះ មិនតាមដំបូន្មានអញទេ ឯងកុំបន្ទោសថាអញចិត្តអាក្រក់ " ។

ឯគោ លុះបានស្ដាប់លានិយាយរឿងប្រាប់សព្វគ្រប់ហើយ ក៏ស្រយុតចិត្តភិតភ័យមហិមា ខ្លាចអន្តរាយរកអ្វីប្រៀបមិនបាន ហើយបន្លឺនូវសម្រែកជាកិរិយាត្អូញថ្ងូរគ្រប់ប្រការ តាមភាសាខ្លួនក្នុងវេលានោះ ។

នាយពាណិជបានឮសត្វទាំងពីរ ចរចាគ្នាទៅវិញទៅមក ដូច្នេះហើយ ក៏អស់សំណើចតែម្នាក់ឯងក្នុងទីនោះ ភរិយាដែលអង្គុយនៅជាមួយ ក៏កើតងឿងឆ្ងល់ទើបដណ្ដឹងសួរទៅស្វាមីថា “អ្នកសើចអ្វីខ្លាំងម្ល៉េះ ចូរប្រាប់ខ្ញុំឱ្យដឹង ខ្ញុំនឹងសើចជាមួយផង” ប្ដីឆ្លើយប្រាប់ថា “នាងគ្រាន់តែស្ដាប់បងសើចក៏បានហើយ កុំចាំបាច់ចង់ដឹងរឿងរ៉ាវអ្វី” ប្រពន្ធថា “ទេ ! ខ្ញុំមិនព្រម ខ្ញុំចង់តែដឹងដើមទងអំពីសំណើចរបស់អ្នក សូមប្រាប់ខ្ញុំទើបខ្ញុំសុខចិត្ត” ប្ដីប្រាប់ទៀតថា “បងនឹងបំពេញចំណង់របស់នាងមិនបានទេ នាងគ្រាន់តែដឹងថា ដែលបងសើចនោះ គឺសើចនឹងពាក្យដែលលានឹងគោនិយាយគ្នា តែប៉ុណ្ណេះបានហើយ ឯដំណើររឿងរ៉ាវ ដែលវាថាដូចម្ដេចៗនោះ បងប្រាប់មិនបានទេ ព្រោះជាការស្ងាត់កំបាំងរបស់បង” ប្រពន្ធឆ្លើយថា “នរណាហាមមិនឱ្យអ្នកនិយាយរឿងស្ងាត់កំបាំងនោះប្រាប់ខ្ញុំ ” ប្ដីប្រាប់ថា “បើបងប្រាប់នាងទៅជីវិតបងនឹងអន្តរាយក្នុងវេលានេះមិនខាន” ប្រពន្ធឆ្លើយថា “អ្នកឯងកុហកខ្ញុំ ពាក្យដែលអ្នកនិយាយនេះមិនពិត បើអ្នកមិនព្រមប្រាប់ខ្ញុំឱ្យត្រង់ពីរឿង ដែលអ្នកសើចទេ ហើយមិនព្រមឱ្យខ្ញុំដឹងអំពីសត្វលានឹងគោនិយាយដូចម្ដេចទេ ខ្ញុំប្ដេជ្ញាចិត្តស្បថចំពោះព្រះដែលគង់នៅខាងលើថា យើងទាំងពីរនាក់ច្បាស់ជាមិនបានរស់នៅជាមួយគ្នាតទៅទៀតបាន” ថាតែប៉ុណ្ណោះ ក៏ស្ទុះចូលទៅក្នុងផ្ទះ ហើយអង្គុយក្នុងកៀនមួយស្រែកទ្រហោយំខ្សឹកខ្សួលលុះអស់រាត្រី ។ ឯប្ដីក៏ដេកតែម្នាក់ឯងក្នុង



វេលាយប់នោះ លុះព្រឹកឡើងឃើញភរិយាអាត្មានៅ តែខ្សឹកខ្សួលក៏បន្ទោសថា “នាងធ្វើយ៉ាងនេះមិនត្រូវទេ យំសោក ព្រោះតែរឿងប៉ុណ្ណេះ ការនេះបើទុកជានាងបានដឹងទៅ ក៏គ្មានប្រយោជន៍អ្វីសោះឯចំណែកបងត្រូវតែលាក់ ព្រោះជាត្រណមយ៉ាងតឹងរបស់បងត្រូវនាងលែងគិតអំពីរឿងនេះទៀតទៅ” ប្រពន្ធឆ្លើយឡើងថា “ខ្ញុំនៅតែគិតលុះត្រាតែអ្នកនិយាយ ប្រាប់ខ្ញុំទើបខ្ញុំលែងយំ” ប្ដីនិយាយទៀតថា “បងបានប្រាប់នាងដោយច្បាស់លាស់ថា បើបងប្រាប់តាមចំណង់ឆ្កួតរបស់នាងនោះខ្លួនបងនឹងស្លាប់មិនខានម្ដេចក៏នៅតែមិនព្រមជឿ” ប្រពន្ធឆ្លើយទៀតថា “បើត្រូវស្លាប់ក៏ស្លាប់ទៅចុះ ស្រេចនូវសង្ខាររបស់ខ្លួននឹងឱ្យខ្ញុំសុខចិត្តលែងសួរលែងចង់ដឹងរឿងនោះខ្ញុំមិនលែងទេ” ប្ដីនិយាយតទៅទៀតថា “បើអញកែឯងមិនឡើង ឯងនៅតែចចេសចង់ស្លាប់ដូច្នេះតោងហៅកូនចៅឱ្យមកជួបជុំ ឱ្យបានទាន់ដង្ហើមមុនដែលឯងនឹងផុតខ្យល់ទៅ” ថាតែប៉ុណ្ណេះក៏ប្រើមនុស្សឱ្យទៅហៅកូនចៅមកជួបជុំហើយហៅ ទាំងអាពុកម្ដាយនឹងបងប្អូននាងនោះទាំងប៉ុន្មានមកផងលុះមកជួបជុំគ្នា ហើយនាយពាណិជក៏និយាយរឿងប្រាប់តាមដំណើរសត្វគ្រប់ឱ្យស្ដាប់ទាំងអស់គ្នា ក៏ចូលទៅលួងលោមនិយាយពន្យល់ដោយន័យផ្សេងៗ ដើម្បីឱ្យលះបង់គំនិតអាក្រក់នោះចោលចេញ តែនាងមិនព្រមទទួលស្ដាប់ពាក្យនោះឡើយ ។ ត្រូវការតែស្ដាប់រឿងនោះឱ្យបាន បើមិនបានស្ដាប់សុខចិត្តតែស្លាប់ ឯកូនទាំងប៉ុន្មាននាក់

ដែលឃើញម្តាយមិនព្រមស្តាប់ដូច្នោះ ហើយក៏ស្រែកយំទ្រហឹងអឹងកងក្នុងវេលានោះ ចំណែកនាយពាណិជ ក៏មិនដឹងគិតផ្លូវណាអង្គុយកើតទុក្ខម្នាក់ឯងនៅមាត់ទ្វារផ្ទះពិចារណា ថាគួរធ្លាយប្រាប់ទៅស៊ូស្លាប់ខ្លួនឯង ឬគួរកុំនិយាយបណ្តោយឱ្យភរិយាអាត្មាស្លាប់វិញ គិតទៅគិតមកមិនដឹងជាត្រូវសម្រេចតាមគំនិតណាឡើយ ។

ឯនាយពាណិជបានចិញ្ចឹមមាន់ញី៥០ នឹងមាន់គក ១នៅក្នុងភូមិនោះ ហើយមានឆ្កែ១ សម្រាប់ការពារសត្វទាំងនោះផង វេលាដែលនាយពាណិជកំពុងតែអង្គុយគិតម្នាក់ឯង ដើម្បីរកឧបាយណាដែលស្រួលល្អស្រាប់តែឃើញឆ្កែស្ទុះទៅសង្គ្រប់មាន់គកដែលកំពុងជាន់ញី ហើយឮឆ្កែស្តីទ្រគោះឱ្យមាន់ថា "អាគកឯងហៅពេញជាព្រើលគ្មានដឹងអ្វីសោះ អាឯងច្បាស់ជាព្រះលោកមិនឱ្យរស់នៅយូរប៉ុន្មានឡើយ ឯងគ្មានព្រួយបារម្ភទេឬ? បានជាឯងត្រេកត្រអាលការកាល់ញីតាមអំពើចិត្តដូច្នេះ ក្នុងថ្ងៃនេះ" វេលានោះមាន់គកស្ទុះលោតឡើងទៅលើគំនរឧសហើយស្រែកសួរទៅឆ្កែវិញ ដោយព្រងើយឥតភ័យថា "នែ៎បងសុនខ ខ្ញុំឆ្ងល់ណាស់ ហេតុអ្វីក៏ត្រូវតមក្នុងថ្ងៃនេះពីថ្ងៃមុនៗម្តេចក៏មិនតមផង" ឆ្កែតបវិញថា "បើឯងមិនដឹងអញនឹងប្រាប់" នែអាគកចូរឯងដឹងថា ក្នុងថ្ងៃនេះម្ចាស់ស្រីគាត់ចង់ដឹងរឿងដែលម្ចាស់ប្រុសប្រាប់មិនបាន បើប្រាប់ទៅនឹងអន្តរាយដល់ជីវិតអញ ភ័យក្រែងម្ចាស់ប្រុសអត់ប្រាប់មិនបាន ព្រោះគាត់ស្រឡាញ់ម្ចាស់ស្រីពន់ពេក



ឯម្ចាស់ស្រីចចេសទទូចចង់ដឹងណាស់អង្វរយ៉ាងណាក៏មិនស្តាប់ ចេះតែអង្គុយយំទង្គិះខ្សឹកខ្សួល ហើយអញឃើញម្ចាស់ប្រុសព្រួយចិត្តអាណិតប្រពន្ធគាត់ផង ស្តាយជីវិតខ្លួនផង ហេតុនេះបានជាយើងព្រួយបារម្ភទាំងអស់គ្នា មានតែឯងមួយគ្មានគិតដល់ទុក្ខគេសោះ ចេះតែរត់ដេញកាល់ញីលេងតាមទំនើងចិត្តឯង ។

ឯមាន់គកកាលបើបានឮឆ្កែស្តីបន្ទោសដូច្នោះហើយ ក៏ឆ្លើយតបថា "ម្នាលបងសុនខ ម្ចាស់យើងពេញជាខ្លៅណាស់ប្រពន្ធតែមួយប្រដៅឱ្យបានបទដូចចិត្តមិនបាន បងឯងមើលខ្ញុំវិញប្រពន្ធដល់ទៅ ៥០ ខ្ញុំប្រដៅឱ្យរបបទាំងអស់ តែមួយក៏មិនហ៊ានខ្ទើកឱ្យទើសចិត្តខ្ញុំ" ។ ម្ចាស់យើងល្ងង់ក្រៃលែង បើចង់ឱ្យបាត់ព្រួយចិត្តជាការងាយសោះ ឆ្កែស្រែកសួរថា "ឯងថាងាយ តើត្រូវឱ្យម្ចាស់យើងធ្វើដូចម្តេច មាន់គកឆ្លើយថា ត្រូវឱ្យម្ចាស់ប្រុសចូលទៅក្នុងបន្ទប់ ដែលម្ចាស់ស្រីនៅបិទទ្វារឱ្យជិតហើយយកដំបងមួយយ៉ាងធំល្មមទៅសំពងបាន ១០០ កុំប្រណីបើធ្វើដូច្នេះហើយខ្ញុំហ៊ានសន្យាថា ម្ចាស់ស្រីច្បាស់ជានៅស្ងៀមទៅវិញលែងចង់ដឹងរឿងរ៉ាវនោះទៀត វេលានោះនាយពាណិជស្តាប់មាន់និយាយស្ទើរតែមិនផុតសេចក្តី ក៏ស្ទុះក្រោកយកដំបងមួយដើរចូលទៅ ឯប្រពន្ធដែលកំពុងតែខ្សឹកខ្សួលតាំងបិទទ្វារជិតនៅតែពីរនាក់ ក៏ពឹតសំពងអស់ទំហឹងឥតប្រណី" លុះត្រាតែនាងនោះអត់មិនបានស្រែកអង្វរថា "ប៉ុណ្ណឹងហើយៗ ម្ចាស់ប្តីអើយវាយប៉ុណ្ណឹងចុះ ខ្ញុំលែងសួរ

លែងចង់ដឹងទៀតហើយ” កាលណាឮប្រពន្ធស្រែកខ្លាំងសន្យាថា នឹងបោះបង់គំនិតចាស់ចោលដូច្នេះហើយ នាយពាណិជក៏ឈប់វាយស្មុះទៅ បើកទ្វារឱ្យបងប្អូនកូនចៅទាំងអស់គ្នាចូល អ្នកទាំងអស់ក៏មានសេចក្តីសោមនស្សក្នុងវេលានោះ ដោយបានឃើញនាងចុះសំរុងស្រួលទៅវិញ ទើបនិយាយសរសើរដល់ប្រាជ្ញានាយពាណិជចេះរកឧបាយមកកែបាន ។ លុះចប់រឿងនេះហើយ អគ្គមហាសេនាប្រាប់ទៅនាងសែរ៉ាសាដជាកូនថា “ឯងនេះ ក្រែងតែអញធ្វើឱ្យដូចជានាយពាណិជធ្វើប្រពន្ធ ទើបឯងបោះបង់សេចក្តីចចេសនេះចេញបាន” ។

នាងសែរ៉ាសាដឆ្លើយតបវិញថា ខ្ញុំសូមលោកអាពុកអនុញ្ញាតទោសខ្ញុំម្តងទៀត សុំឱ្យលោកអាពុកកុំយល់ថាការដែលខ្ញុំចចេសនេះជាការអាក្រក់ឡើយ ឯរឿងនាងប្រពន្ធពាណិជនោះ មិនអាចមកប្រៀបនឹងសេចក្តីចំណង់របស់ខ្ញុំបានទេ ខ្ញុំនឹងនាំរឿងរ៉ាវជាច្រើន ដែលជាឧបាយនាំឱ្យលោកអាពុកលែងឃាត់ខ្ញុំក៏បាន តែថាជាការខាតពេលវេលា បើដូច្នេះខ្ញុំគ្រាន់តែជម្រាបលោកអាពុកថា ដែលលោកអាពុកឃាត់ខ្ញុំជាការឥតអំពើ បើទុកជាលោកអាពុកមិនព្រមអនុញ្ញាតឱ្យខ្ញុំគង់តែនឹងចចេសទៅឱ្យដល់ស្តេចខ្លួនឯងមិនខាន ។

ឯអគ្គមហាសេនា កាលឃាត់កូនមិនបានដូច្នោះ ក៏ទៅទាំងខឹងចូលទៅគាល់ស៊ុលតង់សារ្យា ហើយទូលថាល្ងាចនេះនឹងនាំនាង សែរ៉ា-សាដ ជាកូនមកថ្វាយ ។



កាលនោះ ស៊ុលតង់សារ្យា មានសេចក្តីឆ្ងល់អំពីកិរិយារបស់អគ្គមហាសេនា ទើបទ្រង់ត្រាស់សួរថា “ចុះហេតុអ្វីបានជាដាច់ចិត្តយកកូនបង្កើតមកឱ្យយើងដូច្នេះ” ។

មហាមាត្យក្រាបទូលថា “កូនទូលព្រះបង្គំជាខ្ញុំចង់មកខ្លួនវាឃាត់មិនស្តាប់ វាថាឥតស្ញើបរូញរាអ្វីនឹងសេចក្តីស្លាប់ ដែលរង់ចាំនោះសោះឡើយ វាថាឱ្យតែបានបម្រើព្រះករុណាជាម្ចាស់មួយរាត្រីវាសុខចិត្តទទួលស្លាប់ឥតមានតូចចិត្ត” ស៊ុលតង់ឆ្លើយប្រាប់ថា អគ្គមហាសេនា បើដូច្នោះអ្នកកុំភ្លេចថ្ងៃស្អែកយើងនឹងប្រគល់នាងសែរ៉ាសាដឱ្យអ្នកយកទៅពិឃាតដោយដៃឯង ប្រសិនបើអ្នកមិនសំលាប់យើងនឹងសម្លាប់អ្នកឯងវិញ ដោយដៃយើងជាប្រាកដ អគ្គមហាសេនាទូលថា “សូមទ្រង់ព្រះមេត្តាប្រោស បើទុកជាទូលព្រះបង្គំអល់ឯក វេរាចិត្តយ៉ាងណាក៏មិនអាចនឹងកន្លងព្រះរាជអាជ្ញាបាន ទូលព្រះបង្គំត្រូវតែសម្រេចព្រះរាជតម្រាស់តាមធម្មតា ដែលធ្លាប់ធ្វើមកវេលានោះ ស៊ុល-តង់សារ្យាព្រមទទួលហើយ ប្រាប់ទៅអគ្គមហាសេនាថា បុត្រីមកថ្វាយពេលណាក៏បានតាមចិត្ត ។

អគ្គមហាសេនាថ្វាយបង្គំលាចេញទៅ ហើយក៏ម្ទីម្ទាទៅប្រាប់នាងសែរ៉ាសាដបុត្រីគ្រប់ប្រការ នាងនោះមានចេក្តីសោមនស្សពន់ប្រមាណ ហាក់ដូចជាបានវត្ថុអ្វីយ៉ាងប្រសើរថ្លៃថ្លាក្នុងលោក នាងអរគុណនឹងអគ្គមហាសេនាជាអាពុកឥតគណនា ហើយលួងលោមបិតា

ដោយមធុរវាចាជាច្រើនប្រការ កុំឱ្យអាពុកព្រួយបារម្ភនឹងខ្លួននាង ត្រូវឱ្យចាំសប្បាយឱ្យអស់ពីចិត្តក្នុងគ្រានេះចុះ ។

រួចពីនោះនាងប្រុងប្រៀបរៀបចំខ្លួន ដើម្បីទៅគាល់ស៊ុលតង់មុននឹងទៅ នាងហៅនាងឌីណារសាដជាប្អូនមកនិយាយថា "នែអូន ! ក្នុងវេលានេះបងមានធុរៈម្យ៉ាងធំ បងសូមឱ្យអូនជួយបងបន្តិចកុំប្រកែកឡើយ" ល្ងាចនេះអាពុកយើងនឹងនាំបងទៅថ្វាយព្រះមហាក្សត្រ ដើម្បីធ្វើជាមហេសីកុំឱ្យអូនមានសេចក្ដីភ័យបារម្ភអ្វីសោះអូនចាំស្ដាប់បងនិយាយប្រាប់ឱ្យច្បាស់ការណ៍ កាលណាបងបានទៅដល់ចំពោះព្រះភ័ក្ត្រស៊ុលតង់នោះ បងនឹងសុំអនុញ្ញាតនាំអូនទៅដេកក្នុងបន្ទប់ ដែលជាក្រឡាព្រះបន្ទំជាមួយផង ដើម្បីឱ្យបងបានឃើញមុខអូន ហើយចរចាប្រស្រ័យនឹងគ្នាក្នុងយប់នេះ បើបងសុំអនុញ្ញាតដូច្នេះបាន ត្រូវអូនចាំសម្ដីបងកុំភ្លេច ថាវេលាព្រឹកស្អែកត្រូវអូនភ្ញាក់ពីព្រលឹមមុនថ្ងៃរះមួយម៉ោង ហើយដាស់បងដោយវាចាថាដូច្នេះ "អ្នកបង ! បើអ្នកបងមិនសម្រាន្តលក់ទេ សូមនិទានរឿងអ្វីមួយដ៏ពីរោះ ដែលអ្នកបងចេះឱ្យខ្ញុំស្ដាប់បន្តិចទំរាំតែថ្ងៃរះឡើង លុះអូននិយាយសុំដូច្នេះហើយ បងក៏ផ្ដើមនិយាយរឿងមួយភ្លាម បងសង្ឃឹមថា រឿងនេះអាចនឹងសង្គ្រោះបណ្ដាជនទាំងអស់គ្នា ឱ្យរួចពីសេចក្ដីក្ដៅក្រហាយបានជាប្រាកដ" ឯនាងឌីណារសាដក៏ព្រមទទួលធ្វើតាមពាក្យទាំងប៉ុន្មានដូចមានខាងលើនេះ ។

លុះដល់ពេលព្រលប់ អគ្គមហាសេនានាំបុត្រីចូលទៅថ្វាយស៊ុលតង់ ហើយថ្វាយបង្គំលាទៅលំនៅអាត្មាវិញ។ ខណៈនោះស្ដេចមានបន្ទូលប្រាប់នាងសែរ៉ាសាដឱ្យបើកមុខចេញ ហើយទ្រង់គយគន់សព្វសព៌ាង្គកាយ ឃើញនាងមានរូបឆោមប្រកបដោយនវលក្ខណ៍ក៏កើតសេចក្ដីស្នេហាប្រតិពទ្ធពន់ប្រមាណ តែទ្រង់មានសេចក្ដីសន្ទិះសង្កាក្នុងព្រះហឫទ័យ ដោយឃើញនាងនោះទង្គឹះខ្សឹកខ្សួល ទើបមានព្រះរាជឱង្ការត្រាស់សួរហេតុនៃសេចក្ដីសោយសោកនោះ នាងក៏ក្រាបទូលថា "បពិត្រព្រះសម្មតិទេវាវង្ស បានជាខ្ញុំម្ចាស់ខ្សឹកខ្សួលនេះព្រោះខ្ញុំម្ចាស់ឃ្លាតពីប្អូនស្រីមួយ ដែលខ្ញុំម្ចាស់ស្រឡាញ់ពេញចិត្តក្រៃពេកហើយ នាងនោះក៏ស្រឡាញ់ខ្ញុំម្ចាស់ស្មើគ្នា ខ្ញុំម្ចាស់សូមព្រះរាជានុញ្ញាតឱ្យប្អូនខ្ញុំម្ចាស់មកនិទ្រាក្នុងបន្ទប់នេះជាមួយមួយយប់ផង ដើម្បីឱ្យខ្ញុំម្ចាស់បានឃើញមុខនឹងបានផ្ដែផ្ដាំលាស្លាប់ សូមព្រះអង្គកុំទ្រង់យល់ទាស់សេចក្ដីសុំរបស់ខ្ញុំម្ចាស់នេះឡើយ ព្រោះខ្ញុំម្ចាស់បានរស់នៅតែក្នុងយប់នេះទៀតទេ" ។ វេលានោះស៊ុលតង់សារ្យាទ្រង់បើកព្រះរាជានុញ្ញាតឱ្យហើយឱ្យទៅនាំខ្លួននាងឌីណារសាដមកក្នុងពេលនោះ លុះដល់ពេលផ្ទំស្ដេចនាំនាងសែរ៉ាសាដឡើងលើគ្រែទែនអាសនៈយ៉ាងខ្ពស់តាមទម្លាប់មហាក្សត្រ នាងឌីណារសាដក៏នៅដេកលើគ្រែមួយខាងក្រោមដែលបានរៀបទុកក្នុងទីនោះ ។

លុះពេលទៀបភ្លឺ នាងឌីណារសាដក៏ក្រោកឡើងម្ទីម្ទាតាមពាក្យបណ្ដាំបង ហើយស្រែកសួរទៅបងថា "អ្នកបង ! បើមិនទាន់





សម្រាន្តលក់ទេ សូមនិទានរឿងអ្វីមួយដ៏ពីរោះដែលអ្នកបងចេះឱ្យប្អូនស្តាប់បន្តិចទម្រាំតែភ្លឺ ឱអ្នកបងអើយ ! ប្រហែលជាប្អូនបានស្តាប់រឿងពីរោះរបស់អ្នកបងតែម្តងនេះទៀតទេ" ។

ឯនាងសែរ៉ាសាដ មុននឹងឆ្លើយតបទៅប្អូន បានទូលសួរស៊ុលតង់ថា "បពិត្រព្រះករុណាជាម្ចាស់ ខ្ញុំម្ចាស់សូមព្រះរាជទានបំពេញបំណងនាងឌីណារសាដជាប្អូនក្នុងវេលានេះ សូមទ្រង់ព្រះករុណាមេត្តាប្រោសអនុញ្ញាតចុះ" ស្តេចឆ្លើយតបថា "អើចូរនាងនិយាយចុះ" នាងស្រែកប្រាប់ប្អូនថាចាំស្តាប់ ហើយទូលទៅស៊ុលតង់សារ្យាឱ្យទ្រង់ ព្រះសណ្តាប់រឿងដែលនាងនឹងនិទានថ្វាយ ទើបនាងចាប់និយាយរឿងនោះឡើង ។

**ចប់ភាគទី២ តែប៉ុណ្ណេះ**

**រឿងក្នុងភាគទី៣ កាន់តែចម្លែកណាស់ទៅទៀត**

**សូមអញ្ជើញមើលតទៅកុំខាន ។**